# ជំពូក ១០

**ស្ត្រីប្រមូលផ្តុំដើម្បីបំពេញតម្រូវការសុខភាពរបស់ខ្លួន** ..... 276

**ការកំណត់គោលដៅសម្រាប់ការរៀបចំក្រុម** ..... 278

ស្រមៃពីសេវាសុខភាពដែលយើងចង់បាន ..... 278

សកម្មភាព៖ តើសេវាសុខភាពដែលសមស្របរបស់ស្ត្រីនឹងមានលក្ខណៈដូចម្តេចទៅ? ..... 279

កសាងភាពជាអ្នកដឹកនាំ និងភាពខ្លាំងយូរអង្វែង ..... 280

**ការបង្កើតយុទ្ធសាស្ត្ររបស់អ្នកដើម្បីការផ្លាស់ប្តូរ** ..... 282

ស្គាល់សត្រូវរបស់អ្នក ស្វែងរកសម្ពន្ធមិត្ត ..... 282

សកម្មភាព៖ បង្កើតផែនទីអំណាច ..... 284

យុទ្ធសាស្ត្រផ្សេងៗសម្រាប់ការរៀបចំ ..... 286

**ការបង្កើតយុទ្ធសាស្ត្រទំនាក់ទំនង** ..... 287

ស្គាល់អតិថិជនរបស់អ្នក ..... 287

សកម្មភាព៖ តើសេវាសុខភាពដែលសមស្របសម្រាប់ស្ត្រី មានលក្ខណៈដូចម្តេចទៅ? ..... 288

បង្កើតសាររបស់អ្នក ..... 289

សកម្មភាព៖ ផ្សព្វផ្សាយសាររបស់អ្នក ..... 290

ការបង្កើតសារតស៊ូមតិដែលមានប្រសិទ្ធភាព ..... 290

**ការបង្កើតចលនាដើម្បីសិទ្ធិទទួលបានការថែទាំសុខភាព** ..... 292

ដាក់សម្ពាធឲ្យរដ្ឋាភិបាលទទួលខុសត្រូវ ..... 292

ការពារសេវាសុខភាពសាធារណៈ ..... 296

គាំទ្រការតស៊ូដើម្បីសុខភាពទាំងអស់គ្នា ..... 298

# ការបង្កើតចលនាសុខភាពស្ត្រី



ការរៀបចំដើម្បីទទួលបាននូវការថែទាំសុខភាពដែលសមស្របនិងទុកចិត្តបាន ចាប់ផ្តើមឡើងនៅពេលដែលស្ត្រីចូលរួមគ្នាកំណត់នូវការផ្លាស់ប្តូរដែលពួកគេត្រូវការនៅក្នុងសហគមន៍ និងនៅក្នុងសេវាសុខភាពរបស់ពួកគេ។ នៅក្នុងដំណើរការតស៊ូដើម្បីសម្រេចបាននូវការផ្លាស់ប្តូរទាំងនេះ ស្ត្រីរៀនស្គាល់គ្នាទៅវិញទៅមក និងកាន់តែរឹងមាំនៅពេលដែលពួកគេចែករំលែកគំនិតយោបល់ និងសមត្ថភាពរបស់ខ្លួន។ ពួកគេរៀនពីរបៀបស្វែងរកសម្ពន្ធមិត្តដែលមានឆន្ទៈក្នុងការគាំទ្រគោលដៅរបស់ខ្លួន និងជួយជាពេលវេលា ធនធាន និងជំនាញដែលស្ត្រីអាចនឹងខ្វះខាត។ តាមរយៈការរៀបចំផែនការ ការអនុវត្ត និងការវាយតម្លៃការតស៊ូរបស់ពួកគេ ស្ត្រីទទួលបានបទពិសោធន៍ក្នុងការរៀបចំយុទ្ធសាស្ត្រដើម្បីសម្រេចនូវគោលដៅរយៈពេលខ្លី និងរយៈពេលវែង។ ហើយស្ត្រីដែលពីមុនមក មិនធ្លាប់បានចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តសហគមន៍ ជារឿយៗបានក្លាយជាអ្នកដឹកនាំ។

នៅពេលខ្លះ អ្នករៀបចំគឺជាអ្នកជិតខាង ឬជាសមាជិកនៃក្រុមក្នុងសហគមន៍មួយ។  បុគ្គលិកសុខាភិបាលដែលមានសមានចិត្ត ក៏អាចផ្តួចផ្តើមឲ្យមានការផ្លាស់ប្តូរ និងអញ្ជើញអ្នករៀបចំសហគមន៍ឲ្យចូលរួមផងដែរ។ នៅពេលខ្លះ អាជ្ញាធរមូលដ្ឋាននឹងគាំទ្រសំណើរបស់សហគមន៍ និងពេលខ្លះទៀតក៏មានជម្លោះផងដែរ។ ការយកចិត្តទុកដាក់ អាចនឹងផ្តោតទៅលើការផ្លាស់ប្តូរលក្ខខណ្ឌ ឬទំនៀមទម្លាប់ក្នុងស្រុក ឬក៏អាចផ្តោតលើការជំទាស់នឹងច្បាប់ ឬគោលនយោបាយរបស់រដ្ឋាភិបាលផងដែរ។ មិនថាមានគោលដៅជាអ្វីនោះទេ នៅពេលដែលស្ត្រីធ្វើការជាមួយគ្នាដើម្បីទទួលបានសេវាសុខភាពល្អប្រសើរនៅក្នុងសហគមន៍  នោះពួកគេជួយបង្កើតឲ្យមានចលនាដើម្បីសុខភាពស្ត្រី ។

# ស្ត្រីប្រមូលផ្តុំដើម្បីបំពេញតម្រូវការសុខភាពរបស់ខ្លួន

កាំឡា (Kamla) អៃសា (Ayesha) និង លីឡា (Leela) គឺជាអ្នកជិតខាងនឹងគ្នា។ ពួកគេរស់នៅក្នុងទីក្រុងអាមេតដាបាត (Ahmedabad) នៃប្រទេសឥណ្ឌា ហើយពឹងផ្អែកលើប្រាក់កាសដែលពួកគេរកបានពីការងារបណ្តែតម្លុងម្កាលដើម្បីទ្រទ្រង់ជីវភាពប្រចាំថ្ងៃរបស់គ្រួសារ។ ពួកគេគឺជាកម្មករធ្វើការនៅផ្ទះ ដោយមិនមាននិយោជកប្រាកដប្រជានោះទេ ហើយពួកគេត្រូវរ៉ាប់រងបង់ថ្លៃចំណាយទិញរបស់របរដោយខ្លួនឯង។ នៅពេលចម្អិនអាហារជាមួយគ្នានៅពេលយប់ ពួកគេដឹងសុខទុក្ខគ្នា ថាពួកគេពិតជាហត់នឿយខ្លាំងណាស់ និងការឈឺចាប់ដោយសារការងាររបស់ពួកគេ។ អៃសា ដែលជាកម្មការិនីរោងចក្រកាត់ដេរ តែងតែឈឺខ្នងជាប់ជានិច្ច, ចំណែកឯ កាំឡា និង លីឡា វិញសុទ្ធតែមានបញ្ហាពិបាកដកដង្ហើម ក្រោយពីរមូលសរសៃធូបពេញមួយថ្ងៃ។ ពួកគេបានសម្រេចចិត្តទៅគ្លីនិកសុខភាពជាមួយគ្នា។ ប៉ុន្តែ គិលានុបដ្ឋាក-យិកា និងបុគ្គលិកដទៃទៀតនៅមណ្ឌលសុខភាពនោះ មិនបានជួយស្ត្រីដោះស្រាយបញ្ហារបស់ពួកគេនោះទេ។ ទោះជាស្ត្រីទាំង៣នាក់នេះខកចិត្តក៏ដោយ ក៏ពួកគេបានសម្រេចចិត្តជជែកជាមួយកម្មករធ្វើការនៅផ្ទះដទៃទៀត ហើយបានកត់សម្គាល់ឃើញថា ពួកគេទាំងអស់សុទ្ធតែមានបញ្ហាប្រហាក់ប្រហែលគ្នា។ ក្រោយពីបានដឹងថាពួកគេមិនមែនមានបញ្ហាតែម្នាក់ឯង ស្ត្រីទាំងនោះក៏បានឯកភាពគ្នាធ្វើការជាមួយគ្នាដើម្បីកែលម្អស្ថានភាពរបស់ខ្លួន។




ស្ត្រីទាំងនោះបាននាំយកកង្វល់របស់ខ្លួន ទៅកាន់ការិយាល័យការងាររដ្ឋ ប៉ុន្តែគ្មាននរណាម្នាក់នៅក្នុងអង្គភាពនេះស្តាប់ពួកគេនោះទេ។ ពួកគេក៏បានសម្រេចចិត្តស្វែងរកជំនួយពីសមាគមស្ត្រីប្រកបរបរផ្ទាល់ខ្លួន (SEWA) ដែលជាសហជីពមួយដឹកនាំដោយស្ត្រីក្រីក្រ ដើម្បីទាមទារសិទ្ធិរបស់ពួកគេ។ អ្នករៀបចំសមាគម បានជួយពួកគេឲ្យបង្កើតផែនការមួយ និងបញ្ជីតម្រូវការមួយផងដែរ។ ដោយមានសមាជិកក្រុមជាស្ត្រីកាន់តែច្រើន ពួកគេមានទំនុកចិត្តក្នុងការត្រឡប់ទៅកាន់ការិយាល័យការងាររដ្ឋជាថ្មីម្តងទៀត។ ដោយប្រឈមមុខនឹងស្ត្រីដែលមានការរៀបចំរចនាសម្ព័ន្ធបានល្អ និងមានឧបករណ៍ក្នុងដៃ លោករដ្ឋលេខាធិការទទួលបន្ទុកការងារ បានបង្ខំចិត្តគាំទ្រការតស៊ូរបស់ពួកគេ។ លោកបានជួយពួកគេបង្កើតឲ្យទំនាក់ទំនងដ៏មានតម្លៃជាមួយអ្នកជំនាញការ និងសកម្មជនដទៃទៀត ដែលភាគច្រើនជាបុរស។ ពួកគេបានសហការគ្នាបង្កើតនូវឧបករណ៍ថ្មីៗដែលមានសុវត្ថិភាពជាងមុនសម្រាប់ការងាររបស់ពួកគេ និងវិធីផ្សេងៗទៀតដើម្បីកែលម្អស្ថានភាពការងារឲ្យប្រសើរឡើង។

ដោយមានព័ត៌មានថ្មីៗ និងការគាំទ្រពីសំណាក់សម្ពន្ធមិត្តថ្មីៗរបស់ពួកគេ ក្រុមស្ត្រីទាំងនោះក៏បានត្រឡប់ទៅកាន់មណ្ឌលសុខភាពក្នុងមូលដ្ឋាន និងបានបញ្ចុះបញ្ចូលបុគ្គលិកសុខាភិបាលឲ្យជួយពួកគេ។ កាំឡា អែសា និងលីឡា បាននាំបុគ្គលិកសុខាភិបាលទៅសួរសុខទុក្ខស្ត្រីដែលកំពុងធ្វើការបណ្តែតនៅឯផ្ទះ ដើម្បីបង្ហាញថា ការងាររបស់ពួកគេអាចបង្កគ្រោះថ្នាក់របៀបណា។ ក្រោយពីបានមើលឃើញស្ថានភាពការងាររបស់ស្ត្រីទាំងនោះ ក្រុមបុគ្គលិកសុខាភិបាលបានយល់ព្រមជួយពួកគេរៀបចំទាមទារឲ្យមានគោលនយោបាយការងារល្អប្រសើរជាងមុន និងទទួលបានសេវាថែទាំសុខភាពកាន់តែប្រសើរនៅមណ្ឌលសុខភាព ផងដែរ។

ស្ត្រីទាំងនោះបានមើលឃើញថា ពួកគេប្រឈមមុខនឹងឧបសគ្គមួយផ្សេងទៀត។ ទោះបីជាពួកគេបានទទួលសេវាថែទាំសុខភាពប្រសើរជាងមុនក្តី ក៏ប៉ុន្តែពួកគេមិនមានលទ្ធភាពទិញថ្នាំដែលពួកគេត្រូវការនោះទេ។ តាមរយៈសមាគម SEWA និងការដកស្រង់បទពិសោធន៍របស់ក្រុមដទៃ ពួកគេបានយល់ឃើញថា ប្រសិនបើស្ត្រីម្នាក់ៗដាក់ប្រាក់សន្សំបន្តិចបន្តួច នោះពួកគេអាចបង្កើតសហករណ៍មួយដែលអាចផ្តល់ថ្នាំទូទៅដែលមានតម្លៃទាបបាន។ ក្រោយពីបានរៀបចំផែនការរួច ស្ត្រីទាំងនោះក៏បានដាក់សំណើរបស់ពួកគេទៅកាន់មន្ត្រីចុះបញ្ជីសហករណ៍នៅក្នុងរដ្ឋរបស់ពួកគេ។ ជាអកុសល្យ មន្ត្រីរូបនោះបានបដិសេធសំណើរបស់ពួកគេ!




ទោះបីជាពួកគេមិនទទួលបានការអនុញ្ញាតឲ្យចុះបញ្ជីសហករណ៍ក្តី ក៏ក្រុមស្ត្រីទាំងនេះនៅតែបន្តសរសេរលិខិត និងនិយាយចេញជាសាធារណៈ ហើយក៏មានស្ត្រីកាន់តែច្រើនឡើងៗបានមកចូលរួមជាមួយពួកគេ។ សមាជិកសមាគម SEWA បានធ្វើការជាមួយគ្នាដើម្បីរៀនសូត្រអំពីអាហារូបត្ថម្ភ សុខភាពបន្តពូជ ជំងឺរបេង និងក្តីកង្វល់ផ្នែកសុខភាពទូទៅផ្សេងៗទៀត។ អ្នកជំនាញការដែលរួសរាយរាក់ទាក់បានជួយពួកគេដាំរុក្ខជាតិដែលអាចយកមកធ្វើថ្នាំបុរាណក្នុងតម្លៃសមរម្យ។

រយៈពេល ២ឆ្នាំក្រោយមក មន្ត្រីចុះបញ្ជីបានយល់ព្រមអនុញ្ញាតឲ្យស្ត្រីទាំងនោះចុះបញ្ជិកាសហករណ៍របស់ពួកគេ។ ចាប់តាំងពីពេលនោះមក ពួកគេត្រូវបានទទួលស្គាល់ជាសហករណ៍ដ៏ចំណានដែលមានឱសថស្ថានសហគមន៍ផ្តល់ថ្នាំក្នុងតម្លៃទាប។ សហករណ៍ក៏បានផលិតថ្នាំបុរាណមួយចំនួនផងដែរ ហើយក្រុមមួយត្រូវបានបង្កើតឡើងដើម្បីតាមដានសេវាសុខភាពក្នុងមូលដ្ឋានដើម្បីធានាថា ពួកគេអាចបំពេញតម្រូវការរបស់ស្ត្រី និងគ្រួសាររបស់ពួកគេបាន។ ជាងពាក់កណ្តាលនៃសមាជិកទាំងអស់ ១៤០០ នាក់ មានតួនាទីជាបុគ្គលិកសុខាភិបាលសហគមន៍ អ្នកអប់រំសុខភាព និងឆ្មប។ សហករណ៍ដែលបង្កើត និងគ្រប់គ្រងដោយក្រុមស្ត្រីក្រីក្រនេះ បានជួយកែលម្អស្ថានភាពសុខភាពរបស់គ្រួសារជាច្រើននៅក្នុងសហគមន៍ និងបានពង្រឹងអំណាចសេដ្ឋកិច្ច និងនយោបាយរបស់ស្ត្រី។

# ការកំណត់គោលដៅសម្រាប់ការរៀបចំក្រុម

នៅពេលដែលអ្នកចាប់ផ្តើមការងាររៀបចំក្រុម ការកំណត់គោលដៅច្បាស់លាស់គឺជាកិច្ចការសំខាន់ដែលក្រុមរបស់អ្នកត្រូវធ្វើ។ អ្នកចាំបាច់ត្រូវមានសមត្ថភាពប្រាប់អ្នកដទៃពីអ្វីដែលអ្នកចង់ធ្វើការផ្លាស់ប្តូរ និងពីមូលហេតុរបស់វា។ អ្នកអាចកែប្រែគោលដៅរបស់អ្នក ឬកំណត់គោលដៅថ្មីៗស្របពេលដែលស្ថានការណ៍មានការផ្លាស់ប្តូរ ហើយអ្នកទទួលបានការរីកចម្រើនក្នុងអំឡុងពេលនោះ។ គោលដៅទីមួយរបស់ស្ត្រីនៃសមាគម SEWA គឺបញ្ចុះបញ្ចូលឲ្យអាជ្ញាធរការងារក្នុងមូលដ្ឋានទទួលស្គាល់បញ្ហាដែលពួកគេបានជួបប្រទះក្នុងឋានៈជាស្ត្រីកម្មការិនី។ ក្រោយពីសម្រេចគោលដៅនេះដោយជោគជ័យរួចមក ពួកគេក៏បានកំណត់គោលដៅថ្មីមួយ គឺការធ្វើឲ្យថ្នាំពេទ្យ និងការថែទាំសុខភាពកាន់តែងាយស្រួលស្វែងរកសម្រាប់ប្រជាជន។ កន្លងមកទៀត នៅពេលដែលពួកគេទទួលបានបទពិសោធន៍និងអំណាច និងបង្កើតបាននូវទំនាក់ទំនងបន្ថែមជាមួយក្រុមដទៃ ពួកគេអាចកំណត់គោលដៅកាន់តែធំជាងមុន។




## ស្រមៃពីសេវាសុខភាពដែលយើងចង់បាន

ដើម្បីបង្កើតគោលដៅប្រកបដោយជោគជ័យ យើងចាំបាច់ស្រមើស្រមៃឲ្យបានច្បាស់លាស់បំផុតតាមដែលអាចធ្វើទៅបានអំពីការផ្លាស់ប្តូរដែលយើងចង់ធ្វើឲ្យកើតមានឡើង។ ប៉ុន្តែ វាអាចជាការលំបាកសម្រាប់គ្រប់គ្នា ទាំងបុគ្គលិកសុខាភិបាល និងសមាជិកសហគមន៍ ក្នុងការស្រមៃអំពីសេវាសុខភាពដែលខុសប្លែកពីអ្វីដែលកំពុងមាន និងធ្លាប់មានតាំងពីយូរលង់មកហើយ។ ខាងក្រោមនេះគឺជាគំនិត និងសកម្មភាពមួយចំនួនដែលអាចជួយដល់ក្រុមក្នុងការបង្កើតនូវសំណើជាក់លាក់ដើម្បីការផ្លាស់ប្តូរនៅក្នុងការផ្តល់សេវាសុខភាព។


www.hesperian.org health guides

អ្នកអាចប្រើប្រាស់សកម្មភាពនេះដើម្បីចាប់ផ្តើមកិច្ចពិភាក្សាស្រមើស្រមៃអំពីការកែលម្អសេវាសុខភាពសម្រាប់ស្ត្រី។ អ្នកអាចនឹងចង់អនុវត្តសកម្មភាពនេះជាថ្មីជាមួយក្រុមផ្សេងៗនៅក្នុងសហគមន៍ ដូចជា អង្គការយុវជន ក្រុមស្ត្រី មេដឹកនាំស៊ីវិល ឬបុគ្គលិកសុខាភិបាល ហើយបន្ទាប់មក ធ្វើការចែករំលែកគំនិតរបស់អ្នកទាំងអស់គ្នានៅក្នុងកិច្ចប្រជុំធំមួយ។

## សកម្មភាព — តើសេវាសុខភាពដែលសមស្របរបស់ស្ត្រីនឹងមានលក្ខណៈដូចម្តេចទៅ?

1. ស្នើឲ្យក្រុមរៀបរាប់ពីប្រភេទស្ត្រីខុសៗគ្នានៅក្នុងសហគមន៍ដែលមានលទ្ធភាពតិចបំផុតក្នុងការទទួលសេវាសុខភាព ឬដែលទទួលបានសេវាមិនសមស្រប ឬដោយគ្មានការទទួលស្វាគមន៍រាក់ទាក់។ ជាឧទាហរណ៍ ស្ត្រីវ័យក្មេង ជនជាតិភាគតិច ស្ត្រីពិការ ស្ត្រីនិយាយភាសាផ្សេង ឬស្ត្រីរកស៊ីផ្លូវភេទ។

2. ស្នើឲ្យក្រុមស្រមើស្រមៃថាតើគេអាចផ្តល់សេវាសុខភាពដល់ស្ត្រីទាំងអស់ដោយរបៀបណា។ តើសេវាសុខភាពគួរមានលក្ខណៈបែបណា ទើបចាត់ទុកថាសមស្រប ទទួលយកបាន?

   ខាងក្រោមនេះជាសំណួរមួយចំនួនទៀតដែលអ្នកអាចសួរដើម្បីជួយក្រុមឲ្យស្រមៃអំពីការកែលម្អសេវាសុខភាព ៖

   - តើប្រភេទណាខ្លះនៃក្រុមគាំទ្រ ដែលមានតម្លៃ?
   - តើឥរិយាបថ និងព័ត៌មានប្រភេទណាខ្លះដែលអ្នកផ្តល់សេវាសុខភាពគួរមាន?
   - តើតេស្ត និងការពិនិត្យសុខភាពប្រភេទណាខ្លះដែលគួរផ្តល់?
   - តើមណ្ឌលសុខភាពអាចផ្តល់សេវាដល់ស្ត្រីដែលរស់នៅតំបន់ឆ្ងាយ និងមិនមានមធ្យោបាយធ្វើដំណើរដោយរបៀបណា?
   - តើសេវាសុខភាពអាចកែលម្អការថែទាំសម្រាប់ស្ត្រីមានជំងឺយូរអង្វែងដោយរបៀបណា?

3. ចូរសរសេរពីគំនិតរបស់គ្រប់គ្នានៅលើក្រដាសមួយផ្ទាំងធំ ឬនៅលើក្តារខៀន ដើម្បីឲ្យក្រុមទាំងមូលអាចមើលឃើញ។

   បន្តការពិភាក្សាដោយសួរថា តើនរណានឹងជាប់ពាក់ព័ន្ធនៅក្នុងសេវាសុខភាពសមស្របទាំងនេះ? សួរសំណួរដូចជា៖ តើស្ត្រីគ្រប់វ័យអាចមានសំឡេងនិងវិធីចូលរួមក្នុងការអភិវឌ្ឍសេវាទាំងនេះដោយរបៀបណា? តើបុរសអាចចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកែលម្អសេវាសុខភាពសម្រាប់ស្ត្រីដោយរបៀបណា?

   ជាចុងក្រោយ ចូររំលឹកឡើងវិញនូវរាល់គំនិតដែលធ្វើឲ្យសេវាសុខភាពកាន់តែអាចប្រើប្រាស់បាន កាន់តែសមស្រប និងកាន់តែអាចទទួលយកបានសម្រាប់ស្ត្រីគ្រប់រូប។

4. ប្រសិនបើនៅសល់ពេលវេលា ស្នើឲ្យពួកគេធ្វើការជាគូ ឬជាក្រុមតូចៗដើម្បីបង្កើតរូបភាព ជញ្ជាំងផ្ទាំងគំនូរ បណ្តុំរូបភាពពីទស្សនាវដ្តីនិងកាសែត ឬនិពន្ធបទចម្រៀងឬកំណាព្យ ដែលឆ្លុះបញ្ចាំងពីទស្សនវិស័យមួយបង្ហាញពីលក្ខណៈសមស្របដែលសេវាសុខភាពគួរតែមាន។ អ្នកអាចចែករំលែកសិល្បៈនេះជាមួយអ្នកដទៃនៅក្នុងសហគមន៍ ដើម្បីលើកកម្ពស់ការពិភាក្សាអំពីការកែលម្អសេវាសុខភាពសម្រាប់ទាំងអស់គ្នា។

សកម្មភាពបំផុតគំនិត ដូចជាសកម្មភាពមួយនៅក្នុងទំព័រ 279 ក្នុងនោះប្រជាជនស្រមៃអំពីសេវាសុខភាពសមស្របរបស់ពួកគេ គឺជាសកម្មភាពដ៏អស្ចារ្យសម្រាប់លើកទឹកចិត្តពួកគេ។ ក្រោយពីប្រមូលគំនិតរបស់ពួកគេ ជំហានបន្ទាប់គឺជ្រើសរើសគំនិតដែលត្រូវយកមកអនុវត្តមុនគេ។ គំនិតទាំងនេះនឹងក្លាយជាគោលដៅរបស់អ្នក។ ចូរចាប់ផ្តើមដោយការបែងចែកគំនិតដែលមានលក្ខណៈស្រដៀងគ្នា តែត្រូវបង្ហាញផ្សេងគ្នាជាក្រុម។ ជាឧទាហរណ៍ "យើងត្រូវការឆ្មបដែលចេះនិយាយភាសារបស់យើង" និង "យើងត្រូវការអ្នកបកប្រែបន្ថែម" គឺជាតម្រូវការដែលមានលក្ខណៈស្រដៀងគ្នាខ្លាំងណាស់។ អ្នកក៏អាចបែងចែកគំនិតជាក្រុមៗ អាស្រ័យទៅលើកត្តាថាតើគំនិតទាំងនោះជាគោលដៅរយៈពេលខ្លី ឬរយៈពេលវែង។ សូមមើលសកម្មភាព "បង្កើតផែនការសកម្មភាព" (ទំព័រ 26)។ នៅពេលដែលគំនិតទាំងនោះត្រូវបានរៀបចំយ៉ាងច្បាស់ៗនៅលើក្រដាសផ្ទាំងធំ ឬក្តារខៀន អ្នកអាចសាកល្បងអនុវត្តសកម្មភាព "បោះឆ្នោតជាមួយនឹងចំណុច" (ទំព័រ 225)។ សកម្មភាពនោះអាចជួយឲ្យអ្នកថ្លឹងថ្លែងពីគំនិតផ្សេងៗដើម្បីស្វែងរកគំនិតដែលគេចង់ធ្វើការផ្តោតមុនគេបង្អស់។

# កសាងភាពជាអ្នកដឹកនាំ និងភាពខ្លាំងយូរអង្វែង

ការគិតអំពីរបៀប ដែលអ្នកចង់សម្រេចនូវគោលដៅរបស់អ្នក គឺមានសារសំខាន់ស្មើរស្មើនឹងការគិតអំពីគោលដៅផ្ទាល់ផងដែរ។ តើអ្នកចង់ឲ្យក្រុមរបស់អ្នកលេចត្រដែតឡើងនៅពេលចប់ការតស៊ូដោយរបៀបណា? តើអ្នកសង្ឃឹមថានឹងបានរៀនសូត្រអ្វីខ្លះក្នុងអំឡុងពេលនេះ? តើក្រុមរបស់អ្នកមានបំណងបង្កើនភាពខ្លាំង និងអំណាចនៅក្នុងដំណើរការតស៊ូដើម្បីសម្រេចគោលដៅរបស់ក្រុមតាមវិធីណាខ្លះ?

ជាឧទាហរណ៍ នៅពេលដែលស្ត្រី ៣នាក់នៅក្នុងទីក្រុងអាមេតដាបាត បានចាប់ផ្តើមការងារតស៊ូ, គោលដៅរបស់ពួកគេគឺដើម្បីទាមទារឲ្យមណ្ឌលសុខភាពផ្តល់ការថែទាំព្យាបាលបញ្ហាសុខភាពដែលទាក់ទងនឹងការងាររបស់ពួកគេ។ ដើម្បីសម្រេចគោលដៅនេះ ពួកគេបានយល់ឃើញថា ពួកគេចាំបាច់ត្រូវបង្កើតសម្ពន្ធភាពមួយជាមួយក្រុមដែលបានរៀបចំបង្កើតឡើងរួចហើយ ពួកគេចាំបាច់ត្រូវស្វះស្វែងរកជំនួយពីអ្នកជំនាញការ និងសកម្មជន ពួកគេចាំបាច់ត្រូវមានសមត្ថភាពប្រឈមមុខជាមួយអ្នកកាន់អំណាច ហើយពួកគេចាំបាច់គិតគូរអំពីដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតសម្រាប់បញ្ហាចាស់ៗ (ដូចជាថ្នាំពេទ្យមានតម្លៃខ្ពស់ ។ល)។



ទោះបីជាពួកគេបរាជ័យក្នុងការទាក់ទាញឲ្យមណ្ឌលសុខភាពយកចិត្តទុកដាក់ចំពោះពួកគេក៏ដោយ ក៏ប៉ុន្តែពួកគេនៅតែសម្រេចបាននូវវឌ្ឍនភាពការងារជាច្រើន។ ពួកគេបានស្គាល់អ្នកជំនាញការផ្នែកសុខភាព និងសុវត្ថិភាពមួយចំនួន ហើយពួកគេបានរៀនសូត្រអំពីបញ្ហាសុខភាពការងារ។ ការណ៍នេះជួយជំរុញឲ្យពួកគេសម្រេចបាននូវការកែលម្អលក្ខខណ្ឌការងាររបស់ពួកគេ។ នៅក្នុងដំណើរការនេះ ក្រុមស្ត្រីបានអភិវឌ្ឍជំនាញភាពជាអ្នកដឹកនាំ និងមានអារម្មណ៍ថាខ្លួនមានកម្លាំងបន្តការតស៊ូទាមទារនូវការថែទាំសុខភាពកាន់តែប្រសើរជាងមុន។ ជាលទ្ធផល ពួកគេអាចមើលឃើញខ្លួនឯងជាសមាជិកសហគមន៍ដែលមានសំឡេងក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេ។ ទាំងនេះគឺជាសមិទ្ធផលដ៏ធំធេង។

ចុះប្រសិនបើស្ត្រីទាំងនោះបានទទួលជោគជ័យដោយគ្មានការតស៊ូអ្វីទាំងអស់វិញ តើវានឹងទៅជាយ៉ាងណា? ចូរស្រមៃថា ស្ត្រីទាំងនោះកំពុងនាំយកសំណើរបស់ពួកគេទៅកាន់មណ្ឌលសុខភាព ហើយបញ្ហារបស់ពួកគេក៏ត្រូវបានដោះស្រាយភ្លាម។ នោះនឹងក្លាយជាសមិទ្ធផលដ៏ធំមួយសម្រាប់សហគមន៍របស់ពួកគេ ហើយស្ត្រីទាំងនោះក៏នឹងសប្បាយចិត្តជាមួយនឹងគោលដៅរយៈពេលខ្លីរបស់ខ្លួនផងដែរ។ ក៏ប៉ុន្តែ ពួកគេនឹងមិនទទួលបានបទពិសោធន៍ដ៏មានតម្លៃពីការកសាងភាពជាអ្នកដឹកនាំ ជំនាញ និងអំណាចជាក្រុមនោះទេ ហើយកត្តាទាំងនេះគឺជាធាតុផ្សំដ៏សំខាន់ក្នុងការឈានទៅសម្រេចនូវការផ្លាស់ប្តូររយៈពេលយូរអង្វែង។

ប្រសិនបើអ្នកកំពុងត្រៀមខ្លួនធ្វើយុទ្ធនាការដើម្បីសម្រេចគោលដៅរយៈពេលខ្លីក្នុងការកែលម្អសេវាសុខភាពនៅក្នុងសហគមន៍របស់អ្នក ចូរពិចារណាពីគោលដៅដែលនឹងពង្រឹងជំនាញរៀបចំ និងជំនាញភាពជាអ្នកដឹកនាំរបស់ក្រុមអ្នកផងដែរ។ នៅពេលក្រោយ ប្រសិនបើអ្នកវាយតម្លៃយុទ្ធសាស្ត្ររបស់អ្នក ចូរសំឡឹងមើលរបៀបដែលអ្នកបានកសាងក្រុមរបស់អ្នក និងបានទទួលអំណាចនៅក្នុងដំណើរការនេះ ទន្ទឹមនឹងការវិនិច្ឆ័យរបៀបដែលអ្នកសម្រេចបាននូវគោលដៅរយៈពេលខ្លីរបស់អ្នក។



# ការបង្កើតយុទ្ធសាស្ត្ររបស់អ្នកដើម្បីការផ្លាស់ប្តូរ

នៅពេលដែលអ្នកបានកំណត់គោលដៅរួចហើយ ជំហានបន្ទាប់គឺការកំណត់ថានរណាដែលនឹងរងឥទ្ធិពលពីការផ្លាស់ប្តូរដែលកើតឡើង (ពេលខ្លះ គេហៅថា "អ្នកពាក់ព័ន្ធ") និងការសម្រេចចិត្តថាតើសកម្មភាពអ្វីដែលអ្នកចាំបាច់ត្រូវអនុវត្តដើម្បីឈានទៅសម្រេចគោលដៅរបស់អ្នក។

# ស្គាល់សត្រូវរបស់អ្នក ស្វែងរកសម្ពន្ធមិត្ត

នៅក្នុងសាច់រឿងរបស់ កាំឡា អែសា និង លីឡា ស្ត្រីទាំង៣នាក់មានក្តីសង្ឃឹមថា បុគ្គលិកសុខាភិបាលនឹងក្លាយជាសម្ពន្ធមិត្តរបស់ពួកគេ ប៉ុន្តែបានទទួលការខកចិត្តនៅពេលដែលបុគ្គលិកសុខាភិបាលទាំងនោះមិនអើពើនឹងបញ្ហារបស់ពួកគេទៅវិញ។

ទោះបីជាគោលដៅរបស់អ្នកមិនមានភាពចម្រូងចម្រាសក៏ដោយ ប៉ុន្តែអ្នកខ្លះអាចនឹងជំទាស់នឹងគំនិតរបស់អ្នក។ ជាឧទាហរណ៍ អ្នកគឺជាផ្នែកមួយនៃក្រុមដែលធ្វើការដើម្បីបើកគ្លីនិកយុវជននៅក្នុងសាលារៀនមួយ នោះអាចនឹងមានមនុស្សមួយចំនួនមិនគាំទ្រអ្នក ពីព្រោះពួកគេ ៖

- មានអារម្មណ៍ថាមិនត្រូវបានបញ្ចូលក្នុងដំណើរការនោះ។ នៅក្នុងឧទាហរណ៍នេះ មាតាបិតាសិស្ស និងគ្រូបង្រៀនមួយចំនួនអាចនឹងចង់ចូលរួមពាក់ព័ន្ធផងដែរ ប៉ុន្តែមានអារម្មណ៍ថាគំនិតរបស់ពួកគេមិនត្រូវបានគេស្តាប់។
- មានចម្ងល់ថាតើការផ្លាស់ប្តូរដែលអ្នកបានស្នើឡើង ពិតជាចាំបាច់ដែរឬយ៉ាងណា។ ឧទាហរណ៍ វេជ្ជបណ្ឌិតមួយចំនួនអាចនឹងមិនជឿថា យុវវ័យត្រូវការសេវាសុខភាពពិសេស ឬដោយសារពួកគេមិនមានសក្តិកម្ម ឬក៏ដោយសារពួកគេមិនចាប់អារម្មណ៍ទៅលើទស្សនៈរបស់អ្នកដទៃ។
- មានអារម្មណ៍ថា គោលដៅរបស់អ្នក មិនសមស្របនឹងប្រពៃណីនិងជំនឿ ឬតម្លៃសាសនា និងសីលធម៌ក្នុងស្រុក។ ឧទាហរណ៍ មាតាបិតាសិស្ស និងគ្រូបង្រៀនមួយចំនួនអាចនឹងមានអារម្មណ៍ថា ការបង្កលក្ខណៈងាយស្រួលឲ្យស្ត្រីវ័យក្មេងទទួលបានមធ្យោបាយពន្យារកំណើត នឹងលើកទឹកចិត្តពួកគេឲ្យសកម្មខាងរួមភេទ។
- មានអារម្មណ៍ថា គោលដៅរបស់អ្នក គំរាមកំហែងជីវភាព ទ្រព្យសម្បត្តិ ឬឋានៈក្នុងសង្គមរបស់ពួកគេ។ ឧទាហរណ៍ ម្ចាស់ឱសថស្ថានអាចនឹងជំទាស់នឹងសេវាសុខភាពថ្មីៗ ប្រសិនបើពួកគេជឿថា ពួកគេនឹងបាត់បង់អាជីវកម្ម ប្រសិនបើមនុស្សវ័យក្មេងអាចទទួលថ្នាំពេទ្យដោយឥតគិតថ្លៃ ឬក្នុងតម្លៃទាប។



ផ្ទុយមកវិញ មនុស្សជាច្រើននឹងគាំទ្រអ្នក ពីព្រោះពួកគេមានអារម្មណ៍ថាពួកគេទទួលបានភាពខ្លាំង និងថាមពលដោយសារកិច្ចខិតខំប្រឹងប្រែងរបស់អ្នក។ ការរៀបចំក្រុមរបស់អ្នកអាចនឹងនាំមកនូវសម្ព័ន្ធមិត្តថ្មីៗជាច្រើនដែលយល់ស្របជាមួយគោលដៅរបស់អ្នក ព្រមទាំងអ្នកដទៃដែលចុះសម្រុងជាមួយក្រុមដោយសារហេតុផលជាក់ស្តែង! ពួកគេអាចនឹងគាំទ្រអ្នក ពីព្រោះពួកគេ ៖

- ទទួលផលប្រយោជន៍ដោយផ្ទាល់ពីគម្រោងរបស់អ្នក។ ឧទាហរណ៍ សិស្សានុសិស្សនឹងមានអារម្មណ៍រំភើបចិត្តដោយសារគំនិតផ្តល់នូវគ្លីនិកយុវជនជាមួយនឹងសេវាដែលពួកគេត្រូវការ និងការថែទាំដោយរក្សាការសម្ងាត់។ ពួកគេនឹងគាំទ្រកិច្ចខិតខំប្រឹងប្រែងរៀបចំក្រុមរបស់អ្នក ហើយនឹងរីករាយដែលមាននរណាម្នាក់បោះជំហានជាមួយនឹងទំនុកចិត្តដើម្បីបង្កើតឲ្យមានការផ្លាស់ប្តូរ។
- ចង់ក្លាយជាផ្នែកមួយនៃការបង្កើតការផ្លាស់ប្តូរដែលផ្តល់ផលប្រយោជន៍។ សកម្មជនសុខភាពដែលបានចូលរួមរួចជាស្រេចក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកែលម្អសេវាសុខភាព នឹងគាំទ្រឲ្យមានការបង្កើតគ្លីនិកយុវវ័យមួយ ព្រមទាំងអ្នកដទៃទៀតនៅក្នុងសហគមន៍ដែលយកចិត្តទុកដាក់ចំពោះយុវវ័យ។ ពួកគេចង់ធ្វើឲ្យសហគមន៍ និងពិភពលោកក្លាយជាទីកន្លែងដ៏ប្រសើរមួយ ហើយអ្នកកំពុងបង្កើតឱកាសសម្រាប់ពួកគេដើម្បីផ្តល់ជំនួយ។
- មើលឃើញពីទំនាក់ទំនងរវាងគោលដៅរបស់អ្នក និងគោលដៅរបស់ពួកគេ ទោះបីជាគោលដៅនោះមានភាពខុសគ្នាក៏ដោយ។ ឧទាហរណ៍ គិលានុបដ្ឋាក-យិកាដែលធ្វើការហួសកម្លាំងនៅមណ្ឌលសុខភាព អាចនឹងមើលឃើញថាគ្លីនិកសុខភាពក្នុងសាលាគឺជាមធ្យោបាយមួយដើម្បីបន្ថយបន្ទុកការងាររបស់ពួកគេ ព្រមទាំងលើកកម្ពស់សុខភាពរបស់មនុស្សគ្រប់រូប។ ការគាំទ្រដំណើរការរៀបចំក្រុមរបស់អ្នក អាចជួយបង្កើនការយល់ដឹងរបស់សហគមន៍អំពីបញ្ហាដែលពួកគេជួបប្រទះ។
- មើលឃើញថា វាអាចដំណើរការជាជំនួយសម្រាប់ពួកគេ។ នៅពេលខ្លះ អ្នកគាំទ្រអាចនឹងមិនមានជំនឿលើគោលដៅរបស់អ្នកទេ ប៉ុន្តែមើលឃើញថា ការតស៊ូក្នុងនាមជាតំណាងរបស់អ្នក នឹងនាំមកនូវផលប្រយោជន៍ផ្សេងៗ។ ឧទាហរណ៍ បុគ្គលិកក្រសួងអប់រំ អាចនឹងមិនយល់ស្របជាមួយនឹងតម្រូវការឲ្យមានគ្លីនិកតាមសាលានោះទេ ប៉ុន្តែគាត់មើលឃើញថា អ្នកប្រកបវិជ្ជាជីវៈក្នុងវិស័យសុខាភិបាល គ្រូបង្រៀន និងមាតាបិតាសិស្សគាំទ្រសំណើនេះ ដូច្នេះគាត់ក៏គាំទ្រសំណើនេះដែរ ដើម្បីបញ្ចៀសបញ្ហាចម្រូងចម្រាស និងទទួលបានកេរ្តិ៍ឈ្មោះដោះស្រាយបញ្ហាប្រកបដោយភាពវិជ្ជមាន។




សកម្មភាព "បង្កើតផែនទីអំណាច" (មើលខាងក្រោម) អាចជួយអ្នកឲ្យបង្កើតនូវយុទ្ធសាស្ត្រមួយ ដោយកំណត់សម្ព័ន្ធមិត្តរបស់អ្នក និងសត្រូវរបស់អ្នក ព្រមទាំងអ្នកដែលនៅអព្យាក្រឹត្យ ឬមិនទាន់សម្រេចចិត្តផងដែរ។

## សកម្មភាព — បង្កើតផែនទីអំណាច

គេអាចប្រើប្រាស់ផែនទីអំណាចដើម្បីបង្កើតយុទ្ធសាស្ត្រ កំណត់សម្ពន្ធមិត្តសំខាន់ៗ និងរៀបចំផែនការដើម្បីធ្វើការឈានទៅសម្រេចគោលដៅជាក់លាក់ណាមួយ។ ឧទាហរណ៍នេះបង្ហាញពីរបៀបដែលក្រុមយុវវ័យមួយដែលធ្វើការដើម្បីកែលម្អសេវាសុខភាពសម្រាប់មនុស្សវ័យក្មេង អាចប្រើប្រាស់ផែនទីអំណាច។

សកម្មភាពនេះអាចត្រូវបានធ្វើឡើងនៅក្នុងអំឡុងកិច្ចប្រជុំជាច្រើន ដូច្នេះក្រុមអាចប្រមូលព័ត៌មានមកវិញ និងបន្ថែមពីលើផែនទី។

1. ចូរសរសេរការផ្លាស់ប្តូរដែលអ្នកស្វះស្វែងរក នៅលើចំណុចកណ្តាលនៃក្រដាសមួយផ្ទាំងធំ។ ឧទាហរណ៍ "បង្កើតគ្លីនិកយុវវ័យតាមសាលារៀន" ។ គូសរង្វង់មួយព័ទ្ធជុំវិញ។

2. កំណត់គ្រឹះស្ថានដែលមានអំណាចក្នុងការធ្វើឲ្យមានការផ្លាស់ប្តូរនេះ ហើយសរសេរឈ្មោះគ្រឹះស្ថានទាំងនោះនៅជុំវិញរង្វង់។ ឧទាហរណ៍ "រដ្ឋបាលសាលា" "សមាគមមាតាបិតាសិស្ស" ឬ "ក្រសួងអប់រំ។ គូសរង្វង់ទីពីរជុំវិញឈ្មោះគ្រឹះស្ថានទាំងនោះ។

3. គិតដល់មនុស្សមួយចំនួនដែលមានទំនាក់ទំនងជាមួយគ្រឹះស្ថានទាំងនេះ និងសរសេរឈ្មោះ ឬមុខតំណែងពួកគាត់ដូចជា "នាយកសាលា" "ប្រធានសមាគមមាតាបិតាសិស្ស" ឬ "ប្រតិភូក្រសួងអប់រំ" នៅខាងក្រៅរង្វង់។ ពួកគាត់គឺជាទិសដៅចម្បងសម្រាប់ការងាររៀបចំក្រុមរបស់អ្នក។

4. ពិភាក្សាដើម្បីកំណត់ថាតើមនុស្សទាំងនេះជាអ្នកគាំទ្រ (+) អ្នកជំទាស់ (-) ឬជាអ្នកមិនទាន់សម្រេចចិត្ត (?) អំពីការផ្លាស់ប្តូរដែលអ្នកស្វះស្វែងឲ្យមានឡើង។ ដាក់សញ្ញា + ឬសញ្ញា - ឬសញ្ញា ? នៅជាប់នឹងឈ្មោះ ឬមុខតំណែងពួកគាត់។ គូសរង្វង់ទីបីជុំវិញ។

5. គិតអំពីមនុស្សទាំងអស់ដែលអាចមានឥទ្ធិពលទៅលើបុគ្គលដែលជំទាស់ ឬមិនទាន់សម្រេចចិត្ត រួចសរសេរឈ្មោះឬមុខតំណែងរបស់ពួកគេនៅក្នុងរង្វង់ថ្មីមួយ។ ជាឧទាហរណ៍ ក្រុមយុវវ័យនោះអាចនឹងសរសេរ "គ្រូពេទ្យក្នុងស្រុក" "មេដឹកនាំសាសនា" ឬ "ប្រតិភូក្រសួងសុខាភិបាល។ បុគ្គលទាំងនេះគឺជាទិសដៅបន្ទាប់បន្សំសម្រាប់ការងាររៀបចំក្រុមរបស់អ្នក។ គូសបន្ទាត់ភ្ជាប់បុគ្គលទាំងនេះជាមួយអ្នកដទៃទៀតដែលអាចមានឥទ្ធិពល។



## សកម្មភាព បង្កើតផែនទីអំណាច (ត)

6 ពិភាក្សាដើម្បីកំណត់ថាតើមនុស្សទាំងនេះជាអ្នកគាំទ្រ (+) អ្នកជំទាស់ (-) ឬជាអ្នកមិនទាន់សម្រេចចិត្ត (?) រួចសរសេរនិមិត្តសញ្ញាជាប់នឹងឈ្មោះរបស់គាត់។




7 ពិនិត្យមើលផែនទីទំនាក់ទំនងដោយប្រុងប្រយ័ត្ន។ ស្នើឲ្យក្រុមពិចារណាពីសំណួរផ្សេងៗដូចជា តើសម្ពន្ធមិត្ត (អ្នកដែលគាំទ្រ) ស្ថិតនៅទីណា? តើពួកគេស្និទ្ធនឹងគ្រឹះស្ថានដែលមានអំណាចទៅលើការផ្លាស់ប្តូរដែលយើងចង់បានក្នុងយ៉ាងដូចម្តេច? តើឱកាសល្អៗបំផុតសម្រាប់មានឥទ្ធិពលទៅលើបុគ្គលសំខាន់ៗនៅក្នុងគ្រឹះស្ថានទាំងនោះស្ថិតនៅឯណា? ជាការសំខាន់ផងដែរដែលត្រូវពិចារណាពីអត្ថប្រយោជន៍ និងហានិភ័យនៃការគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់អ្នកសម្រាប់បុគ្គល និងគ្រឹះស្ថានផ្សេងៗនៅលើផែនទីអំណាច? ការស្វែងយល់ពីមូលហេតុដែលពួកគេអាចនឹងជំទាស់នឹងកិច្ចខិតខំប្រឹងប្រែងរបស់អ្នក ក៏នឹងជួយអ្នកឲ្យបង្កើតបាននូវយុទ្ធសាស្ត្រដោះស្រាយបញ្ហាប្រឈមដែលអ្នកអាចនឹងប្រឈមមុខផងដែរ។

8 ជាមួយនឹងព័ត៌មានដែលអ្នកប្រមូលបាន ចូរបង្កើតផែនការមួយសម្រាប់ប្រមែប្រមូលការគាំទ្រពីសម្ពន្ធមិត្តដែលអាចជួយឲ្យអ្នកមានឥទ្ធិពលទៅលើបុគ្គល និងគ្រឹះស្ថានដែលអ្នកត្រូវការឲ្យមកគាំទ្រអ្នកដើម្បីអាចសម្រេចនូវគោលដៅរបស់អ្នក។

ការអនុវត្តសកម្មភាពផែនទីអំណាចឡើងវិញរៀងរាល់ពីរបីខែម្តង គឺជាវិធីដ៏ល្អមួយដើម្បីបន្តវាយតម្លៃ ថាតើយុទ្ធសាស្ត្រដែលបានបង្កើតឡើងកំពុងមានប្រសិទ្ធភាពដែរឬអត់ និងដើម្បីកែសម្រួលផែនការរបស់អ្នកដើម្បីបញ្ចូលសម្ពន្ធមិត្តថ្មី។

# យុទ្ធសាស្ត្រផ្សេងៗសម្រាប់ការរៀបចំ

នៅពេលដែល កាំឡា អែសា និង លីឡា បានចាប់ផ្តើមជជែកគ្នាអំពីបញ្ហាសុខភាពរបស់ពួកគេ គឺពួកគេកំពុងតែអនុវត្តនូវជំហានដំបូងដែលសំខាន់បំផុតក្នុងការរៀបចំក្រុម។ ពួកគេកំពុងតែបំបែកភាពនៅទីទៃពីគ្នា និងក៏កំពុងបង្កើតការស្វែងយល់រួមគ្នាអំពីបញ្ហាដែលពួកគេបានជួបប្រទះផងដែរ។ បន្ទាប់មក ពួកគេប្រឈមមុខនឹងអ្នកនៅមណ្ឌលសុខភាព និងនៅការិយាល័យការងារ ដែលជាអ្នកមានអំណាចអាចជួយពួកគេឲ្យផ្លាស់ប្តូរលក្ខខណ្ឌការងាររបស់ពួកគេ និងលទ្ធភាពទទួលបានសេវាសុខភាពរបស់ពួកគេ។ ខណៈដែលពួកគេបានធ្វើការជាមួយសមាគម SEWA ពួកគេបានបង្កើតយុទ្ធសាស្ត្រផ្សេងៗដែលពួកគេអាចប្រើប្រាស់ដើម្បីសម្រេចនូវគោលដៅរបស់ពួកគេ។

**បង្កើតការឯកភាពជាឯកច្ឆ័ន្ទ** (កុងសុងស៊ីស) ៖ ប្រសិនបើអ្នកនយោបាយ និងបុគ្គលិកសុខាភិបាលចង់សហការ និងទទួលយកសំណើ នោះក្រុមអាចនឹងព្យាយាមបង្កើតកុងសុងស៊ីសដើម្បីបង្កើតការផ្លាស់ប្តូរដែលគ្រប់គ្នាអាចយល់ស្របគ្នាដោយគ្មានជម្លោះ។ ការណ៍នេះអាចនឹងមានភាពងាយស្រួលជាងវិធីសាស្ត្រផ្សេងៗទៀត ប៉ុន្តែវាអាចដំណើរការទៅបានលុះត្រាតែគ្រប់គ្នាបានយល់ស្របរួចជាស្រេចអំពីការផ្លាស់ប្តូរណាខ្លះដែលចាំបាច់ត្រូវមាន។ កាំឡា អែសា និង លីឡា បានព្យាយាមបង្កើតកុងសុងស៊ីសជាមួយបុគ្គលិកសុខាភិបាលនៅឯគ្លីនិក និងជាមួយការិយាល័យការងារ ប៉ុន្តែពួកគេបានរកឃើញថាពួកគេមិនអាចសម្រេចជោគជ័យលើការងារនេះបានឡើយ។ ផ្ទុយមកវិញ ពួកគេត្រូវបង្ខំឲ្យពួកគេយល់ព្រមស្តាប់ ដែលហៅថា "ការយកអំណាច។

**យកអំណាច** ៖ នៅពេលខ្លះ ក្រុមអាចនឹងចាំបាច់ត្រូវយកអំណាចមួយចំនួនពីអ្នកដែលគ្រប់គ្រងការសម្រេចចិត្ត។ ពួកគេធ្វើដូច្នេះដោយប្រើប្រាស់ភាពខ្លាំងសមូហភាព និងសកម្មភាពសាធារណៈ ដើម្បីបង្ខំអ្នកមានអំណាចឲ្យយល់ព្រមប្រគល់អំណាច។ តើការងារនេះដំណើរការទៅយ៉ាងដូចម្តេច? ហេតុអ្វីបានជាអ្នកមានអំណាចយល់ព្រមប្រគល់សិទ្ធិអំណាចមួយចំនួន ឬទាំងអស់របស់ពួកគេទៅលើអ្វីដែលកើតឡើង? ជារឿយៗ អ្នកមានអំណាចនឹងផ្លាស់ប្តូរជំហាររបស់ពួកគេ មិនមែនតែដោយសារការបញ្ចុះបញ្ចូលដោយការតវ៉ាបែបសីលធម៌នោះទេ ប៉ុន្តែដោយសារសម្ពាធពីសាធារណជនដែលធ្វើឲ្យពួកគេគ្មានជម្រើសផ្សេង។ ពួកគេបានដឹងថា ការខាតបង់ចំពោះពួកគេដែលបណ្តាលមកពីការមិនប្រគល់អំណាច គឺមានទំហំធំធេងជាងការការខាតបង់ដោយសារការយល់ព្រមប្រគល់អំណាច។ នៅពេលដែល កាំឡា អែសា និង លីឡា បានទៅការិយាល័យការងាររដ្ឋ មន្ត្រីនៅទីនោះបដិសេធសំណើពួកគេដោយមិនខាតបង់អ្វីទាំងអស់។ ប៉ុន្តែនៅពេលដែលក្រុមស្ត្រីដ៏ធំមួយដែលមានការរៀបចំល្អបង្ហាញខ្លួននៅចំពោះមុខពួកគេ និងនិយាយច្បាស់ៗថាពួកគេនឹងមិនចាកចេញទេ នោះលោករដ្ឋលេខាធិការទទួលបន្ទុកការងារក៏បានលះបង់អំណាចមួយចំនួនរបស់គាត់។ លោកបានទទួលយកការទាមទាររបស់ពួកគេ ហើយស្ត្រីទាំងនោះក៏បានទទួលអំណាច។




នៅពេលដែលរោងចក្រស្បែកជើងមួយបានបិទទ្វារនៅក្នុងប្រទេសហុងឌូរ៉ាស នាឆ្នាំ២០១០ និយោជិតដែលភាគច្រើនជាស្ត្រីត្រូវបានបញ្ឈប់ពីការងារដោយគ្មានការទូទាត់សំណងសរុប ២លានដុល្លារ ដែលរោងចក្របានជំពាក់ពួកគេទាំងអស់គ្នា។ ក្រោយពីការតវ៉ារយៈពេលមួយឆ្នាំដោយកម្មករ និងសម្ពន្ធមិត្តរបស់ពួកគេនៅឯបរទេស ម្ចាស់រោងចក្រក៏បានទូទាត់សំណងដែលជំពាក់កម្មករទាំងនោះ និងបានផ្តល់ធានារ៉ាប់រងសុខភាពរយៈពេលមួយឆ្នាំ។

**បង្កើតអំណាច៖** ទោះបីជាការរៀបចំក្រុមបានល្អឥតខ្ចោះ អាចបង្កើតកុងសុងស៊ីស ឬយកអំណាចបានក៏ដោយ ក៏នៅតែមានស្ថានភាពមួយចំនួនដែលទាមទារឲ្យក្រុមបង្កើតរចនាសម្ព័ន្ធថ្មីទាំងស្រុងមួយដោយមិនប្រើប្រាស់បណ្តាញផ្លូវការផងដែរ។ ទោះបីជាស្ត្រីនៃសមាគម SEWA បានបង្ខំឲ្យរដ្ឋលេខាធិការទទួលបន្ទុកការងារងាកមកគាំទ្រការតស៊ូរបស់ពួកគេ ហើយទោះបីជាបុគ្គលិកសុខាភិបាលបានងាកមកយកចិត្តទុកដាក់ចំពោះរបួសពាក់ព័ន្ធនឹងការងារ និងបញ្ហាសុខភាពរបស់ពួកគេក៏ដោយ ក៏ស្ត្រីក្រីក្រនៅក្នុងទីក្រុងអាមេតដាបាត នៅតែមិនមានលទ្ធភាពទិញថ្នាំពេទ្យនៅឡើយ។ ក្នុងនាមជាអ្នករៀបចំក្រុម ពួកគេត្រូវការយុទ្ធសាស្ត្រមួយ។ ពួកគេអាចព្យាយាមបង្កើតកុងសុងស៊ីសជាមួយក្រុមហ៊ុនផលិតឱសថ ដោយស្នើឲ្យពួកគេបញ្ចុះតម្លៃថ្នាំពេទ្យ។ ពួកគេអាចព្យាយាមយកអំណាចពីក្រុមហ៊ុនទាំងនោះ ដោយបង្ខំឲ្យពួកគេបញ្ចុះតម្លៃថ្នាំពេទ្យ។ ឬក៏ពួកគេក៏អាចបង្កើតអំណាចដោយការបង្កើតនូវរចនាសម្ព័ន្ធផ្សេងមួយទាំងស្រុង គឺសហករណ៍ដែលអាចទិញថ្នាំពេទ្យយ៉ាងច្រើនក្នុងតម្លៃទាប យកមកចែកចាយដល់ពួកគេដោយស្មើភាពគ្នា។

ការរៀបចំក្រុមដើម្បីតទល់នឹងមតិសាធារណៈអំពីសេវាសុខភាព (ឬអ្វីមួយផ្សេង) អាចនឹងបង្កឲ្យមានប្រតិកម្មអវិជ្ជមានតបត ដោយសត្រូវរបស់អ្នក អាចនឹងរៀបចំយុទ្ធនាការដើម្បីបំផ្លាញក្រុមរបស់អ្នក និងគោលដៅរបស់អ្នកវិញបាន។ តាមរយៈការបង្កើតនូវកុងសុងស៊ីសថ្មី តាមរយៈការប៉ុនប៉ងយកអំណាចពីបុគ្គលនិងគ្រឹះស្ថាន ឬតាមរយៈការស្វែងរកវិធីដើម្បីបង្កើតអំណាចថ្មី អ្នកអាចនឹងប្រឈមមុខនឹងការជំទាស់ ស្នាមរបួស គ្រោះថ្នាក់ផ្ទាល់ខ្លួន ឬការគំរាមកំហែងដល់រាងកាយទៀតផង។ ការណ៍នេះអាចធ្វើឲ្យក្រុម និងសមាជិកម្នាក់ៗដែលពាក់ព័ន្ធ ប្រឈមនឹងភាពតានតឹងអារម្មណ៍ និងនឿយហត់ជាខ្លាំង។ ទោះជាយ៉ាងនេះក្តី ជារឿយៗមនុស្សកាន់តែមានការប្តេជ្ញាចិត្តខ្លាំងឡើង កាន់តែសាមគ្គី និងកាន់តែមានគំនិតច្នៃប្រឌិតនៅក្នុងការឆ្លើយតបវិញ។

សូម្បីតែការតស៊ូមិនសូវជួបការលំបាកក៏ដោយ ក៏មនុស្សមានការផ្លាស់ប្តូរខណៈដែលពួកគេចូលរួមក្នុងការងាររៀបចំក្រុម។ ពួកគេបង្កើតនូវទំនាក់ទំនងថ្មីៗ ទស្សនៈថ្មីអំពីអំណាចរបស់ពួកគេ និងគំនិតថ្មីៗអំពីអ្វីដែលអាចទៅរួច។ ខណៈដែលអ្នកឈ្នះ (ហើយពេលខ្លះចាញ់) សមរភូមិតស៊ូផ្សេងៗដែលអ្នកជ្រើសរើសចូលរួម អ្នកក៏បានជួយបង្កើតនូវលក្ខខណ្ឌនានាដើម្បីការផ្លាស់ប្តូរកាន់តែច្រើន និងកាន់តែស៊ីជម្រៅផងដែរ។

# ការបង្កើតយុទ្ធសាស្ត្រទំនាក់ទំនង

ការទំនាក់ទំនងច្បាស់លាស់ជាមួយសមាជិកសហគមន៍ សម្ពន្ធមិត្ត និងអ្នកធ្វើសេចក្តីសម្រេចចិត្តអំពីគំនិត ផែនការ និងគោលដៅរបស់អ្នកគឺជាកិច្ចការដ៏មានសារៈសំខាន់សម្រាប់ការបង្កើតការគាំទ្រ និងការមានឥទ្ធិពលទៅលើមតិសាធារណៈ។

## ស្គាល់អតិថិជនរបស់អ្នក

ដើម្បីជូនដំណឹង បញ្ចុះបញ្ចូល និងជំរុញអ្នកដទៃឲ្យគាំទ្រអ្នក ជាដំបូងអ្នកចាំបាច់ស្វែងយល់ពីអ្វីដែលពួកគេបានដឹង គិត និងមានអារម្មណ៍អំពីបញ្ហានោះ និងមូលហេតុ។ ប្រសិនបើអាចស្វែងយល់បានកាន់តែច្រើន នោះអ្នកនឹងអាចត្រៀមខ្លួនបានកាន់តែប្រសើរដើម្បីដោះស្រាយបញ្ហា និងកង្វល់របស់ពួកគេ។

ការគិតអំពីទស្សនិកជន ឬក្រុមផ្សេងៗទាំងអស់ដែលអ្នកកំពុងព្យាយាមបញ្ចុះបញ្ចូលគឺជាកិច្ចការដ៏មានសារប្រយោជន៍។ តើនរណាដែលបានគាំទ្រគំនិតអ្នករួចហើយ? តើនរណាមិនទាន់សម្រេចចិត្តនៅឡើយ? តើនរណាជាអ្នកជំទាស់? នេះអាចជួយដល់អ្នកក្នុងកិច្ចខិតខំប្រឹងប្រែងតស៊ូមតិរបស់អ្នក ខណៈដែលអ្នករៀបចំហេតុផលដើម្បីកៀងគរអ្នកគាំទ្រ និងផ្លាស់ប្តូរគំនិតរបស់អ្នកដទៃ។

ផែនទីគំនិតមានសារប្រយោជន៍សម្រាប់ការគិតអំពីទស្សនិកជនខុសៗគ្នា និងរបៀបដែលអ្នកអាចមានឥទ្ធិពលទៅលើអ្នកដែលមិនទាន់សម្រេចចិត្ត អ្នកដែលជំទាស់នឹងគំនិតរបស់អ្នក និងអ្នកដែលយល់ស្របប៉ុន្តែអាចមានភាពសកម្មកាន់តែខ្លាំងក្នុងការគាំទ្រ។ សកម្មភាពនេះក៏ជួយក្រុមបង្កើតបាននូវសារជាក់លាក់សម្រាប់ទស្សនិកជននីមួយៗ និងរៀបចំជំហានបន្តបន្ទាប់ដែលក្រុមនឹងត្រូវអនុវត្ត។

## សកម្មភាព តើសេវាសុខភាពដែលសមស្របសម្រាប់ស្ត្រី មានលក្ខណៈដូចម្តេចទៅ?

**ការត្រៀម** ៖ ស្នើឲ្យក្រុមពិនិត្យមើលផែនទីអំណាច (ទំព័រ 284) ដែលពួកគេបានបង្កើតឡើងអំពីបញ្ហានេះ។ រៀបចំក្រដាសមួយសន្លឹកធំដែលមានជួរឈរពីឆ្វេងទៅស្តាំសម្រាប់ "សម្ពន្ធមិត្តសកម្ម" "សម្ពន្ធមិត្ត" "អ្នកមិនទាន់សម្រេចចិត្ត" "អ្នកជំទាស់" និង "អ្នកជំទាស់សកម្ម។

1. មើលគ្រឹះស្ថាន ឬក្រុមនៅលើផែនទីអំណាច រួចពិភាក្សាពីគំនិតរបស់ពួកគេនីមួយៗអំពីបញ្ហានេះ មានន័យថា តើពួកគេគាំទ្រ ឬជំទាស់នឹងគោលដៅរបស់អ្នកខ្លាំងកម្រិតណា? សរសេរឈ្មោះក្រុមនីមួយៗនៅក្នុងជួរឈរដែលសមស្របនឹងគំនិតរបស់ពួកគេ (ឧទាហរណ៍ "សម្ពន្ធមិត្ត") និងព័ត៌មានដែលអ្នកមានអំពីកង្វល់របស់ពួកគេ។

2. ស្នើឲ្យក្រុមពិភាក្សាថាតើមានសារអ្វីខ្លះអំពីបញ្ហារបស់អ្នកដែលនឹងមានប្រសិទ្ធភាពបំផុតសម្រាប់មានឥទ្ធិពលទៅលើក្រុមនីមួយៗ និងអ្នកដែលអាចជួយអ្នកក្នុងការផ្សព្វផ្សាយសារនោះ។

3. ជាចុងក្រោយ ស្នើឲ្យក្រុមកំណត់ជំហានសកម្មភាពសម្រាប់បង្កើតយុទ្ធសាស្ត្រទំនាក់ទំនងសម្រាប់ក្រុមនីមួយៗនៅលើផែនទីគំនិត។ ជាឧទាហរណ៍ "ធ្វើការស្រាវជ្រាវបន្ថែមដើម្បីស្វែងរកហេតុផលអាចឲ្យជឿបាន" ឬ "ស្វែងរកសម្ពន្ធមិត្តដើម្បីមានឥទ្ធិពលទៅលើមនុស្សកាន់តែច្រើន។

នេះគឺជាឧទាហរណ៍មួយនៃផែនទីគំនិត ដោយផ្អែកលើឧទាហរណ៍ដដែលនៃគ្លីនិកសុខភាពតាមសាលាពីផែនទីអំណាចដែលបរិយាយនៅទំព័រ 284 ៖

គាំទ្រ ←→ ជំទាស់

| សម្ពន្ធមិត្តសកម្ម | សម្ពន្ធមិត្ត | គ្មានយោបល់ ឬ មិនទាន់សម្រេចចិត្ត | អ្នកជំទាស់ | អ្នកជំទាស់សកម្ម |
|---|---|---|---|---|
| សមាគមសិស្ស | មណ្ឌលសុខភាពសហគមន៍ | ក្រសួងអប់រំ | រដ្ឋបាលសាលា | ឪពុកម្តាយសិស្ស |
| ស្រឡាញ់ពាក្យស្លោក: រាងកាយសុខភាព គ្លីនិករបស់អ្នក | គាំទ្រគ្លីនិកតាមសាលាដើម្បីបន្ថយបន្ទុកការងារនិងកែលម្អសុខភាព | ព្យាយាមបញ្ចៀសភាពចម្រូងចម្រាស | ជំទាស់គ្លីនិកដោយសារត្រូវការចំណាយប្រាក់ | ភ័យខ្លាចថា ការទទួលបានសេវាពន្យារកំណើតនឹងធ្វើឲ្យយុវវ័យសកម្មខាងរួមភេទ |
| | អ្វីដែលត្រូវធ្វើ៖ | អ្វីដែលត្រូវធ្វើ៖ | អ្វីដែលត្រូវធ្វើ៖ | អ្វីដែលត្រូវធ្វើ៖ |
| | ស្នើឲ្យគិលានុបដ្ឋាក-យិកាទៅបញ្ចុះបញ្ចូលអ្នកដទៃឲ្យយល់ពីផលប្រយោជន៍សុខភាពដែលបានមកពីគ្លីនិកតាមសាលា។ | ចាត់តាំងតំណាងសិស្សនិងបុគ្គលិកសុខាភិបាលដើម្បីដាក់ញត្តិស្នើសុំឲ្យមានការបង្កើតគ្លីនិកតាមសាលា។ | បង្កើតថវិកាសាកល្បង (ដោយមានជំនួយពីគ្លីនិកក្នុងមូលដ្ឋាន) ដើម្បីបង្ហាញថា អាចរ៉ាប់រងការចំណាយបាន។ | ស្វែងរកការសិក្សាដែលបង្ហាញលទ្ធផលផ្ទុយពីការភ័យខ្លាចរបស់ពួកគាត់។ សរសេរសំបុត្រទៅនិពន្ធនាយកកាសែត។ បង្កើតខិត្តប័ណ្ណសម្រាប់ផ្សព្វផ្សាយតាមទីសាធារណៈ។ |



www.hesperian.org health guides

# បង្កើតសាររបស់អ្នក

មិនថាអ្នកកំពុងនិយាយនៅចំពោះមុខហ្វូងមនុស្ស កំពុងធ្វើបទបង្ហាញ កំពុងនិយាយជាមួយអ្នករាយការណ៍ព័ត៌មាន កំពុងសរសេរខិត្តប័ណ្ណ ឬកំពុងបង្ហោះសារនៅលើគេហទំព័រនោះទេ ចូរអ្នករៀបចំសាររបស់អ្នកយ៉ាងប្រុងប្រយ័ត្ន។ អ្នកប្រហែលជាត្រូវបង្កើតសារខុសៗគ្នាសម្រាប់ក្រុមមនុស្សខុសៗគ្នាផងដែរ។ សម្រាប់សារនីមួយៗ ចូរពិចារណាពីកត្តាពីរយ៉ាង ៖ តើអ្វីទៅជាគំនិតមួយឬពីរដែលអ្នកចង់ឲ្យទស្សនិកជនរបស់អ្នកចងចាំ និងថាតើការផ្ញើសារនេះនឹងពង្រឹងបុព្វហេតុរបស់អ្នកយ៉ាងដូចម្តេច?

**សារទៅកាន់សម្ពន្ធមិត្តរបស់អ្នក** គួរតែជាការអំពាវនាវឲ្យធ្វើសកម្មភាពដែលផ្តល់នូវវិធីងាយស្រួល និងច្បាស់លាស់សម្រាប់ការចូលរួម។ សារដែលល្អបំផុតស្នើឲ្យមានសកម្មភាពជាច្រើន ដូចជា ការចុះហត្ថលេខាលើញត្តិ ការផ្សព្វផ្សាយព័ត៌មានតាមរយៈបណ្តាញសង្គម ឬការចូលរួមព្រឹត្តិការណ៍ផ្សេងៗ។ បន្តផ្តល់ព័ត៌មានបច្ចុប្បន្នភាពដល់សម្ពន្ធមិត្តរបស់អ្នក និងរក្សាការចូលរួមរបស់ពួកគេយ៉ាងសកម្ម។

**សារទៅកាន់ភាគីអព្យាក្រឹត្យ** ដែលមិនទាន់សម្រេចចិត្ត ឬមិនមានអារម្មណ៍គាំទ្រនៅឡើយ ទាមទារនូវព័ត៌មានដែលនឹងជួយពួកគេចូលរួមជាសម្ពន្ធមិត្ត។ ទោះបីជាទស្សនិកជននេះអាចនឹងបានដឹងរួចមកហើយអំពីបញ្ហាក៏ដោយ ក៏អ្នកនៅតែត្រូវជួយពួកគេឲ្យទទួលបាននូវទស្សនៈថ្មី និងការយកចិត្តទុកដាក់បន្ថែម។ តើសក្ខីកម្មនិងតួលេខអ្វីខ្លះដែលអាចទាក់ទាញពួកគេបាន? ការប្រើប្រាស់រឿងរ៉ាវផ្ទាល់ខ្លួន និងសក្ខីភាពផ្តល់នូវប្រសិទ្ធភាពខ្ពស់ខុសប្លែកពីធម្មតា។



*ដើម្បីបញ្ចុះបញ្ចូលប្រជាជនក្នុងទីក្រុង ម៉ិកស៊ិកូ ស៊ីធី (Mexico City) អំពីបញ្ហា ស្ត្រីស្លាប់ដោយសារការរំលូតកូនដោយគ្មានសុវត្ថិភាព យើងបានចាត់តាំងឲ្យវេជ្ជបណ្ឌិតមួយរូបនិយាយ ពីព្រោះប្រជាជននឹងស្តាប់វេជ្ជបណ្ឌិត។ វេជ្ជបណ្ឌិតរូបនោះបានប្រើប្រាស់ស្ថិតិ រួចបាននិយាយរឿងពិតមួយអំពី ស្ត្រីវ័យក្មេងម្នាក់ដែលបានស្លាប់។ ប្រជាជនអាចស្រមៃដល់ប្អូនស្រី ឬកូនស្រីរបស់ពួកគាត់ដែលអាចប្រឈមនឹងស្ថានភាពដូច ស្ត្រីវ័យក្មេងម្នាក់នេះ។*

**សារទៅកាន់អ្នកជំទាស់** គឺជាសារឆ្លើយតបនឹងការរិះគន់របស់ពួកគេ។ រំពឹងទុកពីហេតុផលរបស់ពួកគេ ហើយត្រៀមការឆ្លើយតបរបស់អ្នក។ វិធីដែលមានប្រសិទ្ធភាពមួយដើម្បីឆ្លើយតបនឹងហេតុផល ឬការរិះគន់គឺផ្តោតការយកចិត្តទុកដាក់ ឬកែសម្រួលការពិភាក្សាឡើងវិញ។




អ្នកជំទាស់អាចនឹងក្រឡៃបញ្ហាដោយស្តីបន្ទោស ឬបន្ទុះបង្អាប់អ្នកដែលត្រូវការសេវាសុខភាព។




អ្នកអាចកែសម្រួលសារដោយបង្ហាញពីរបៀបដែលការថែទាំសុខភាពសម្រាប់គ្រប់គ្នានឹងជួយដល់មនុស្សគ្រប់រូប។

**សកម្មភាព** **ការបង្កើតសារតស៊ូមតិដែលមានប្រសិទ្ធភាព**

ប្រើប្រាស់សកម្មភាពនេះដើម្បីបង្កើត ឬកែលម្អសារតស៊ូមតិរបស់ក្រុមអ្នក និងដើម្បីរៀបចំឯកសារបោះពុម្ពផ្សាយ ឬឯកសារជាលាយលក្ខណ៍អក្សរ។

**ការត្រៀម** ៖ ជ្រើសរើសសារផ្សាយពាណិជ្ជកម្ម ឬសារយុទ្ធនាការនយោបាយជាច្រើនពីទស្សនាវដ្តី កាសែត ឬគេហទំព័រ។ បិទសារទាំងនោះនៅលើជញ្ជាំងតាមទីកន្លែងផ្សេងៗគ្នានៅក្នុងបន្ទប់។

1. បង្កើតក្រុមតូចៗ និងឲ្យសារមួយទៅក្រុមនីមួយ។ ស្នើឲ្យក្រុមមើលសារនោះយ៉ាងប្រុងប្រយ័ត្ន និងគិតអំពីចំណុចដែលពួកគេចូលចិត្តវា និងមូលហេតុដែលធ្វើឲ្យសារនោះមានលក្ខណៈផ្តល់ព័ត៌មាន បញ្ចុះបញ្ចូល ទាក់ទាញ និងរស់រវើក។

2. ស្នើឲ្យក្រុមនីមួយៗចែករំលែកគំនិតរបស់ពួកគេអំពីលក្ខណៈដែលធ្វើឲ្យសារមានប្រសិទ្ធភាព និងផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាពខ្ពស់។ អ្នកអាចសួរសំណួរដូចជា ៖
   - តើសារនេះផ្តោតតែទៅលើក្រុមទស្សនិកជនណាមួយទេឬ?
   - តើអ្វីខ្លះជាជំនឿ ឬឥរិយាបថដែលគេមានជារួមអំពីបញ្ហានោះ ហើយតើសារនេះអាចដោះស្រាយនូវជំនឿ ឬឥរិយាបថដោយរបៀបណា?
   - តើសារនោះមានលក្ខណៈទាក់ទាញទាំងផ្នែកហេតុផល និងអារម្មណ៍យ៉ាងដូចម្តេច ដើម្បីឲ្យមនុស្សងាយយល់ និងចាប់អារម្មណ៍?
   - តើសកម្មភាពអ្វីដែលសារនេះស្នើឲ្យមនុស្សអនុវត្ត?

3. ស្នើឲ្យក្រុមតូចនីមួយៗបង្កើតសារមួយដែលទាក់ទងនឹងការខិតខំតស៊ូមតិរបស់ក្រុមអ្នកផ្ទាល់។ (រំលឹកពួកគេឲ្យគិតអំពីនរណាជាអតិថិជនរបស់ពួកគេ ហើយសារនេះនឹងជូនដំណឹង បញ្ចុះបញ្ចូល និងជំរុញឲ្យទស្សនិកជនអនុវត្តសកម្មភាពនោះ។

4. នៅពេលដែលពួកគេត្រៀមខ្លួនរួចរាល់ ស្នើឲ្យក្រុមតូចនីមួយៗចែករំលែកសាររបស់ពួកគេជាមួយអ្នកដទៃ។ បន្ទាប់មកស្នើឲ្យក្រុមធំពិភាក្សាពីសារនីមួយៗ ហើយផ្តល់មតិត្រឡប់ដល់គ្នាទៅវិញទៅមក។

# ផ្សព្វផ្សាយសាររបស់អ្នក

នៅពេលដែលអ្នកបានសម្រេចចិត្តរួចហើយ ថាតើទស្សនិកជនជាគោលដៅរបស់អ្នកជានរណា សម្រេចថាតើអ្នកនឹងផ្សព្វផ្សាយសាររបស់អ្នកនៅកន្លែងណា និងតាមមធ្យោបាយណា ៖ តាមរយៈបណ្តាញសារព័ត៌មាន ដូចជាអ៊ីនធឺណិត វិទ្យុ ឬកាសែត? ដោយធ្វើផ្ទាំងប៉ាណូ? ដោយផ្តល់ការសំដែង ការពិភាក្សា ឬសុន្ទរកថា?

បណ្តាញសារព័ត៌មាន និងការពិភាក្សាជាសាធារណៈច្រើនតែផ្តល់នូវប្រសិទ្ធភាពខ្ពស់ក្នុងការផ្សព្វផ្សាយទៅដល់មន្ត្រីរដ្ឋាភិបាល មេដឹកនាំនយោបាយ និងទស្សនិកជនធំៗ ខណៈដែលការសំដែងសិល្បៈសហគមន៍ ផ្ទាំងប៉ាណូ និងការសំដែងច្រើនតែមានប្រសិទ្ធភាពសម្រាប់ទស្សនិកជនក្នុងមូលដ្ឋានដែលអាចទទួលបានសារបោះពុម្ព ឬដែលជាធម្មតាមិនចូលរួមក្នុងការពិភាក្សាពីគោលនយោបាយ។

**ស្វែងរកការផ្សព្វផ្សាយពីសារព័ត៌មាន៖** ស្វែងរកអ្នកកាសែតដែលចាប់អារម្មណ៍ចំពោះបញ្ហារបស់អ្នក។ បង្កើតគំនិតនៃរឿងរ៉ាវដែលអ្នកចង់ឲ្យពួកគេផ្សព្វផ្សាយ និងរបៀបដែលអ្នកបង្ហាញអំពីរឿងរ៉ាវនោះ។ ដោយហេតុថាអ្នកកាសែតជារឿយៗយកចិត្តទុកដាក់លើព័ត៌មាន "ដែលមានប្រជាប្រិយភាព" ឬបច្ចុប្បន្នភាព ចូរពន្យល់ពីលក្ខណៈដែលរឿងរ៉ាវរបស់អ្នកមានទំនាក់ទំនងជាមួយព័ត៌មានល្បីៗនាពេលបច្ចុប្បន្ន។ រក្សាទំនាក់ទំនងជាមួយអ្នកសារព័ត៌មាន និងឲ្យពួកគេដឹងពីដំណើរវិវត្តន៍នៃរឿងរ៉ាវរបស់អ្នក។ ជាដំបូងពួកគេប្រហែលជាមិនឆ្លើយតបនោះទេ ប៉ុន្តែប្រសិនបើអ្នកអាចបង្កើតទំនាក់ទំនងមួយបាន នោះពួកគេអាចនឹងសរសេរអំពីអ្នកនៅពេលអនាគត។ អ្នកសារព័ត៌មានភាគច្រើនប្រើប្រាស់តែមួយផ្នែកតូចមួយនៃអ្វីដែលអ្នកបាននិយាយប៉ុណ្ណោះ ដូច្នេះចូរនិយាយឲ្យបានច្បាស់ៗពីចំណុចសំខាន់។ ប្រសិនបើការសន្ទនានោះប្រាសចាកប្រធានបទ ចូរខិតខំត្រឡប់មកនិយាយពីគំនិតសំខាន់ៗរបស់អ្នកវិញ។ កុំភ័យខ្លាចក្នុងការនិយាយឡើងវិញ! ហាត់សមអនុវត្តការសំដែងតួដែលជួយឲ្យអ្នកនិយាយមិនចាកប្រធានបទ ដោយស្នើឲ្យមិត្តម្នាក់បន្តប់អ្នកតាមរយៈការសួរសំណួរដែលមិនពាក់ព័ន្ធនឹងសាររបស់អ្នក។

អ្នកក៏អាចសរសេរសេចក្តីប្រកាសព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកដែលនិយាយអំពីបច្ចុប្បន្នភាពទាក់ទងនឹងសកម្មភាពដែលអង្គការរបស់កំពុងធ្វើ រួចផ្ញើទៅកាន់សារព័ត៌មានដើម្បីចុះផ្សាយផងដែរ។ ជម្រើសមួយផ្សេងទៀតគឺការសរសេរលិខិតទៅកាន់និពន្ធនាយកសារព័ត៌មាន ឬក៏អាចបង្កើត និងផ្សព្វផ្សាយកិច្ចសន្ទនាថតទុកជាមុនរបស់អ្នក ដែលហៅថា "podcast" ផងដែរ។ នេះគឺជាវិធីដ៏ល្អមួយដើម្បីបង្ហាញពីខ្លួនអ្នកដោយប្រើប្រាស់ពាក្យពេចន៍របស់អ្នកផ្ទាល់។



នៅក្នុងតំបន់ជនជាតិឃឹតមួយនៃប្រទេសអ៊ីរ៉ង់ តុលាការមួយបានដាក់ទោសអ្នកបៀតបៀនស្ត្រីម្នាក់ដោយតម្រូវឲ្យគាត់ស្លៀកសម្លៀកបំពាក់ស្ត្រីជាសាធារណៈដើម្បីឲ្យគាត់ខ្មាសគេ។ ជាការឆ្លើយតប ស្ត្រីនិងបុរសបានធ្វើបាតុកម្មតាមដងផ្លូវ ហើយក្រុមមួយដែលហៅខ្លួនឯងថា "ក្រុមបុរសជនជាតិឃឹតដើម្បីសមភាព" បានចាប់ផ្តើមយុទ្ធនាការបណ្តាញសង្គមមួយដែលក្នុងនោះពួកគេបានបង្ហោះរូបថតខ្លួនឯងក្នុងសម្លៀកបំពាក់ស្ត្រីដើម្បីតវ៉ានឹងគំនិតដែលថាការកើតជាស្ត្រីពិតជាគួរឲ្យខ្មាសអៀន។

**ប្រើប្រាស់ទីសាធារណៈ៖** បង្កើតផ្ទាំងរូបភាព ការសំដែងតាមដងផ្លូវ និងសុន្ទរកថាសម្រាប់ផ្សព្វផ្សាយតាមទីសាធារណៈ។ នេះជាជម្រើសដ៏ប្រសើរក្នុងការរក្សាអ្នកគាំទ្ររបស់អ្នក និងទាក់ទាញអ្នកគាំទ្រថ្មី។

**កៀងគរតាមរយៈបណ្តាញសង្គម៖** បណ្តាញសង្គមដូចជា Facebook និង Twitter អាចជាមធ្យោបាយដ៏ឆាប់រហ័ស និងមានប្រសិទ្ធភាពខ្ពស់ក្នុងការទំនាក់ទំនងជាមួយសម្ពន្ធមិត្តរបស់អ្នក។ ប្រសិនបើអ្នកបង្កើតទំព័របណ្តាញសង្គមមួយសម្រាប់អង្គការរបស់អ្នក អ្នកអាចផ្ញើព័ត៌មានបច្ចុប្បន្នភាព លិខិតអញ្ជើញ អត្ថបទ វីដេអូ និងរូបភាពទៅកាន់អ្នកដែលតាមដាន (Followers) ទំព័ររបស់អ្នក។ តាមរយៈការប្រើប្រាស់បណ្តាញសង្គម អ្នកក៏អាចទំនាក់ទំនងជាមួយក្រុមនៅឆ្ងាយៗដែលមានលក្ខណៈស្រដៀងក្រុមរបស់អ្នក ដើម្បីចែករំលែកគំនិត និងបង្កើតសម្ពន្ធមិត្តផងដែរ។ នៅពេលដែលធ្វើការលើគម្រោងដែលមានភាពចម្រូងចម្រាស ចូរពិចារណាការប្រើប្រាស់គណនីអនាមិកដើម្បីធានាសុវត្ថិភាព។ អ្នកអាចធ្វើរបៀបនេះបានដោយការបង្កើតគណនី Facebook មួយដែលមិនមានមិត្តភ័ក្តិ ឬរូបថតសមាជិកក្រុម ប៉ុន្តែមានព័ត៌មានអំពីរបៀបដែលអ្នកមើលអាចចូលរួមបាន។

## ការប្រើប្រាស់បណ្តាញសង្គមដើម្បីបង្កើតតំបន់មានសុវត្ថិភាពសម្រាប់ស្ត្រី

ស្ត្រីអេហ្ស៊ីប ប្រាំបីនាក់ក្នុងចំណោមដប់នាក់ បានរាយការណ៍ថា ពួកគេប្រឈមមុខនឹងការបៀតបៀនតាមដងផ្លូវជារៀងរាល់ថ្ងៃ។ ដើម្បីប្រយុទ្ធប្រឆាំងនឹងការបៀតបៀននេះ មនុស្សមួយក្រុមបានបង្កើតផែនទីបៀតបៀនមួយដើម្បីឲ្យស្ត្រីអាចរាយការណ៍ពីទីកន្លែង និងរបៀបដែលពួកគេទទួលរងការបៀតបៀន។ ក្រុមនេះបានប្រើប្រាស់បណ្តាញសង្គម Twitter និង Facebook ដើម្បីប្រមូលរបាយការណ៍ និងប្រាស្រ័យទាក់ទងជាមួយអ្នកស្ម័គ្រចិត្តដែលធ្វើការអប់រំសហគមន៍ក្នុងតំបន់ដែលមានការបៀតបៀនខ្ពស់។ សកម្មភាពនេះជួយឲ្យអ្នកស្ម័គ្រចិត្តបង្កើត "តំបន់មានសុវត្ថិភាព" នៅតាមតំបន់ទាំងនោះ ដែលអាចឲ្យស្ត្រីធ្វើដំណើរទៅកាន់ទីនោះបាន ប្រសិនបើពួកគេមានអារម្មណ៍ថាគ្មានសុវត្ថិភាព។ ក្រុមក៏មានប្លុក (blog) មួយដែលពួកគេប្រើប្រាស់ដើម្បីផ្តល់នូវធនធានជាច្រើនសម្រាប់អ្នកដែលស្វះស្វែងរកជំនួយ រួមទាំងថ្នាក់រៀនសម្រាប់ការការពារខ្លួនផងដែរ។

# ការបង្កើតចលនាដើម្បីសិទ្ធិទទួលបានការថែទាំសុខភាព

នៅពាសពេញសៀវភៅនេះ មានឧទាហរណ៍ជាច្រើនបង្ហាញពីការរៀបចំមនុស្សដើម្បីកែលម្អសុខភាព និងជីវិតរស់នៅរបស់ស្ត្រី និងក្មេងស្រី។ នៅក្នុងកម្រិតសកលលោក និងកម្រិតក្នុងស្រុក កិច្ចខិតខំប្រឹងប្រែងទាំងនេះបង្កើតបាននូវចលនាដ៏ធំ និងមានភាពចម្រុះមួយ ដែលទាមទារសិទ្ធិទទួលបានការថែទាំសុខភាពសម្រាប់មនុស្សគ្រប់រូប។ ដោយសារមានការរៀបចំជាច្រើនឆ្នាំកន្លងមក មានសន្ធិសញ្ញាអន្តរជាតិជាច្រើនបានប្រកាសថា ស្ត្រី និងក្មេងស្រីមានសិទ្ធិទទួលបានលក្ខខណ្ឌដែលពួកគេត្រូវការដើម្បីរស់រានមានជីវិតប្រកបដោយសុខភាពល្អ (សូមមើលទំព័រ 300 ដល់ 304)។ ទន្ទឹមនឹងកិច្ចព្រមព្រៀងអន្តរជាតិទាំងនេះ ប្រទេសជាច្រើនក៏មានច្បាប់ដែល (យ៉ាងហោចណាស់ក៏មានតែនៅលើក្រដាស) ធានាជូនស្ត្រី និងក្មេងស្រី (និងបុរស និងក្មេងប្រុសផងដែរ) នូវសិទ្ធិទទួលការថែទាំសុខភាព និងលក្ខខណ្ឌជាមូលដ្ឋានសម្រាប់ជីវិតរស់នៅប្រកបដោយសុខភាពល្អ។

នៅក្នុងប៉ុន្មានទំព័របន្ទាប់ យើងនឹងចែករំលែកនូវឧទាហរណ៍មួយចំនួនដែលបង្ហាញពីយុទ្ធសាស្ត្រផ្សេងៗដែលមនុស្សនៅជុំវិញពិភពលោកបានប្រើប្រាស់ដើម្បីការពារសិទ្ធិទទួលបានការថែទាំសុខភាពសម្រាប់មនុស្សទាំងអស់គ្នា។

# ដាក់សម្ពាធឲ្យរដ្ឋាភិបាលទទួលខុសត្រូវ

រដ្ឋាភិបាលជាអ្នកទទួលខុសត្រូវក្នុងការធានាថា សិទ្ធិរបស់ពលរដ្ឋខ្លួនត្រូវបានគោរព។ នៅតាមប្រទេសជាច្រើន រដ្ឋាភិបាលក៏ទទួលខុសត្រូវផ្នែកផ្លូវច្បាប់ក្នុងការផ្តល់ការថែទាំសុខភាព និងសេវាមូលដ្ឋានដទៃទៀត ដូចជាទឹក និងអនាម័យផងដែរ។ ការដាក់សម្ពាធឲ្យរដ្ឋាភិបាលទទួលខុសត្រូវក្នុងការការពារសិទ្ធិរបស់ប្រជាជន និងការផ្តល់នូវការថែទាំសុខភាព និងសេវាមូលដ្ឋានដទៃទៀត អាចជាចំណុចស្នូលដ៏សំខាន់នៃការការរៀបចំក្រុម។

## គណៈកម្មាធិការសុខភាពសហគមន៍

នៅតាមប្រទេសជាច្រើន អ្នករៀបចំបានតស៊ូទាមទារ និងសម្រេចជោគជ័យទទួលបានសិទ្ធិបង្កើតគណៈកម្មាធិការសុខភាពសហគមន៍។ ជារឿយៗ គណៈកម្មាធិការទាំងនេះធ្វើការជាមួយរដ្ឋាភិបាល និងមណ្ឌលសុខភាពដើម្បីសម្រេចថា តើគម្រោងសុខភាពណាខ្លះដែលគួរទទួលបានការផ្តល់មូលនិធិ។ ពួកគេក៏អាចនឹងជួយរៀបអង្គាសប្រាក់សម្រាប់គម្រោងជាក់លាក់ផ្សេងៗ ដូចជាការបណ្តុះបណ្តាលអំពីការលើកកម្ពស់សុខភាពផងដែរ។ គណៈកម្មាធិការសុខភាពអាចវាយតម្លៃសេវាកម្មដែលមណ្ឌលសុខភាពផ្តល់ជូនមតិត្រឡប់ពីសហគមន៍។ ជាឧទាហរណ៍ គណៈកម្មាធិការសុខភាពមួយអាចនឹងវាយតម្លៃថាតើមរណភាពរបស់អ្នកជំងឺអាចបង្ការបានដែរឬអត់ ឆ្លើយតបនឹងពាក្យបណ្តឹងរបស់សហគមន៍ដែលប្តឹងមណ្ឌលសុខភាព និងចាប់ឲ្យមណ្ឌលសុខភាពទទួលខុសត្រូវ នៅពេលដែលចាំបាច់។

សមាសភាពគណៈកម្មាធិការសុខភាពគួរមានសមាជិកសហគមន៍ដែលមានបទពិសោធន៍ និងគំនិតខុសៗគ្នា ជាពិសេសអ្នកដែលសំឡេងរបស់ពួកគាត់ជាធម្មតាមិនត្រូវបានបញ្ចូលក្នុងការពិភាក្សាជាផ្លូវការអំពីវិធីដែលបញ្ហាធ្វើឲ្យប៉ះពាល់ដល់មនុស្សគ្រប់រូបក្នុងសហគមន៍។ ជាការសំខាន់ដែលត្រូវបង្កើតដំណើរការមួយសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តរួមគ្នាក្នុងចំណោមសមាជិកសហគមន៍ បុគ្គលិកមណ្ឌលសុខភាព និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីបញ្ចៀសការខ្វែងគំនិតគ្នាទាក់ទងនឹងថាតើអ្នកណាដែលមានសិទ្ធិអំណាចក្នុងការដោះស្រាយពាក្យបណ្តឹងអំពីសេវាសុខភាព និងធ្វើសេចក្តីសម្រេចចិត្ត។ វិធីមួយដើម្បីធានាថាគ្រប់គ្នាបានចូលរួម គឺការបង្កើតវិធីផ្សេងៗដើម្បីឲ្យសមាជិកសហគមន៍ដែលមានបទពិសោធន៍ច្រើនបង្ហាត់អ្នកដែលមានបទពិសោធន៍តិច។ សមាជិកសហគមន៍ រួមទាំងយុវជន ត្រូវការដឹងពីរបៀបដែលប្រព័ន្ធសុខាភិបាល និងថវិកាដំណើរការ ដើម្បីពួកគេអាចចូលរួមយ៉ាងពេញលេញក្នុងការធ្វើសេចក្តីសម្រេចចិត្តបាន។

## សកម្មជនពិការភាពរៀបចំទីក្រុងដែលសម្រួលដល់ជនពិការ

នៅទីក្រុង អេខាធើរីនប៊ឺក (Ekaterinburg) នៃប្រទេសរុស្ស៊ី មន្ត្រីក្រុងបានបង្កើតកម្មវិធីពិការភាពមួយដើម្បីជួយសម្រួលឲ្យជនពិការកាន់តែងាយស្រួលចូលប្រើប្រាស់។ ប៉ុន្តែ ជនពិការមួយក្រុមបានមើលឃើញថា ទោះបីជារដ្ឋាភិបាលបាននិងកំពុងព្យាយាមជួយពួកគេក៏ដោយ ក៏នៅមានទីកន្លែងជាច្រើនដែលពួកគេបានផ្លាស់ប្តូរនោះ នៅតែពិបាកសម្រាប់ជនពិការប្រើប្រាស់នៅឡើយ។ ដូច្នេះ ពួកគេក៏បានបង្កើតជាក្រុមមួយដែលមានឈ្មោះថា សង្គមសេរីភាពនៃការធ្វើដំណើរ (Freedom of Movement Society) និងបានជួបជាមួយមន្ត្រីក្រុងដើម្បីផ្តល់ជូនពួកគេនូវបញ្ជីរាយនាមមធ្យោបាយសម្រាប់កែប្រែទីក្រុងឲ្យកាន់តែងាយស្រួលសម្រាប់ជនពិការធ្វើដំណើរ។ មន្ត្រីក្រុងបានអនុញ្ញាតឲ្យសមាជិកក្រុម ចូលរួមក្នុងគណៈកម្មាធិការរៀបចំក្រុង និងឲ្យពួកគេរៀបចំបង្កើតគោលការណ៍ណែនាំដែលស្ថាបត្យករអាចប្រើប្រាស់ដើម្បីបង្កលក្ខណៈឲ្យអគារកាន់តែមានភាពងាយស្រួលឲ្យជនពិការប្រើប្រាស់បាន។




## សវនកម្មសង្គម

សវនកម្មសង្គមគឺជាការវាយតម្លៃសាធារណៈទៅលើរបៀបដែលសេវាកម្មផ្សេងៗ ដូចជា សេវាថែទាំសុខភាព ឬសេវាអប់រំ កំពុងបំពេញតម្រូវការរបស់ប្រជាជនដែលពួកគេបម្រើ។ សវនកម្មសង្គមអាចជាមធ្យោបាយដ៏ល្អមួយដើម្បីធ្វើឲ្យងាយស្រួលមើលបញ្ហា បង្កើតការផ្សព្វផ្សាយពីបណ្តាញសារព័ត៌មាន និងបង្កើតនូវតម្រូវការកែលម្អ។ ជាធម្មតា សវនកម្មសង្គមគឺជាការប្រមូលព័ត៌មានតាមរយៈការសម្ភាស ឬការស្ទង់មតិ និងការផ្សព្វផ្សាយលទ្ធផលជាសាធារណៈ។ សំណួរអាចរួមមានដូចជា ៖ តើគ្រប់គ្នាទទួលបានការថែទាំដែលមានគុណភាពដូចៗគ្នាដែរឬទេ? តើសេវាកម្មដែលបានផ្តល់ជូនបំពេញបានតាមតម្រូវការរបស់ប្រជាជនដែរឬទេ? តើមូលនិធិកំពុងត្រូវបានប្រើប្រាស់យ៉ាងដូចម្តេចខ្លះ? តើមានថ្នាំ និងសម្ភារពេទ្យសំខាន់ៗដែរឬទេ?

ប្រសិនបើពួកគេមានបំណងចូលរួម តំណាងពីបុគ្គលិកមណ្ឌលសុខភាព និងអាជ្ញាធរមូលដ្ឋានក៏អាចចូលរួមជាមួយអង្គការសហគមន៍ដើម្បីធ្វើសវនកម្មសង្គមបានផងដែរ។

ខាងក្រោមនេះគឺជាឧទាហរណ៍បង្ហាញពីយុទ្ធនាការមួយដែលបានប្រើប្រាស់សវនកម្មសង្គមមួយប្រភេទនៅក្នុងប្រទេសឥណ្ឌា។

## សវនាការសុខភាពប្រជាជន កែលម្អសេវាសុខភាពនៅប្រទេសឥណ្ឌា

ស្ត្រី "វណ្ណៈទាប" មួយក្រុមនៅទីក្រុង បេងហ្គាល័រ (Bangalore) ប្រទេសឥណ្ឌា មានការខឹងសម្បា នៅពេលដែលដឹងថា មណ្ឌលសុខភាពក្នុងមូលដ្ឋានរបស់ពួកគេ បានទទួលប្រាក់ពីរដ្ឋាភិបាលសម្រាប់ផ្តល់សេវាសុខភាពមូលដ្ឋាន ប៉ុន្តែបែរជាមិនព្រមផ្តល់ទៅវិញ។ ពួកគេបានចូលរួមជាមួយសកម្មជនដទៃទៀត និងបានប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់មួយ ដើម្បីកត់ត្រាសេវាកម្ម និងថ្នាំពេទ្យដែលមណ្ឌលសុខភាពបានផ្តល់ឲ្យពួកគេ ម៉ោងពេលមណ្ឌលសុខភាពបើកដំណើរការ និងសម្ភារបរិក្ខារអ្វីខ្លះដែលមណ្ឌលសុខភាពប្រើប្រាស់។

នៅពេលនោះ យុទ្ធនាការដែលស្ត្រីទាំងនោះបានចូលរួមគឺ Jan Swasthya Abhiyan (JSA) ក៏បានរៀបចំសវនាការសុខភាពប្រជាជនមួយឡើង។ អ្នកជំនាញការដែលមានសមានចិត្តចំពោះពួកគេ និងសម្ពន្ធមិត្តបានដើរតួនាទីជាក្រុម "ចៅក្រម" និងបានស្តាប់ការផ្តល់សក្ខីភាពអំពីរបៀបដែលសិទ្ធិទទួលបានការថែទាំសុខភាពរបស់ប្រជាជនត្រូវបានរំលោភបំពាន។ ស្ត្រីទាំងនោះមានមោទនភាព និងរីករាយជាខ្លាំងដែលត្រូវបានហៅថាជាសាក្សីនៅក្នុងសវនាការនោះ និងបាននិយាយនៅចំពោះមុខប្រជាជនជិត ១០០០នាក់ អំពីអ្វីដែលពួកគេបានរកឃើញនៅក្នុងសវនកម្មមណ្ឌលសុខភាពរបស់ពួកគេ និងបទពិសោធន៍របស់ពួកគេនៅពេលត្រូវបានគេបដិសេធមិនផ្តល់ការថែទាំ។ ការចែករំលែកបទពិសោធន៍របស់ពួកគេ និងការស្តាប់សក្ខីភាពរបស់សកម្មជនដទៃទៀតបានធ្វើឲ្យពួកគេមានកម្លាំងកាន់តែខ្លាំង និងអាចបន្តការទាមទារឲ្យមានការកែលម្អពីសំណាក់មណ្ឌលសុខភាពនោះ។



នៅក្នុងអំឡុង ២ឆ្នាំបន្ទាប់ សវនាការសុខភាពប្រជាជនត្រូវបានគេរៀបចំធ្វើនៅតាមតំបន់ជាច្រើននៃប្រទេសឥណ្ឌា។ បន្ទាប់មក សកម្មជននៃយុទ្ធនាការ JSA ក៏បានចែករំលែកនូវរាល់ឯកសារដែលពួកគេប្រមូលបានជូនដល់គណៈកម្មការជាតិទទួលបន្ទុកសិទ្ធិមនុស្សនៃប្រទេសឥណ្ឌា។ គណៈកម្មការនេះជឿថា ការបដិសេធមិនផ្តល់ការថែទាំសុខភាព គឺជាបញ្ហារំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរមួយ។ ដោយមានការជួយជ្រោមជ្រែងពីគណៈកម្មការនេះ ប្រតិភូយុទ្ធនាការ JSA ជាង ១០០នាក់ និងអ្នកជំនាញការដទៃទៀតបានធ្វើជាកសិណសាក្សីនៅក្នុងសវនាការជាសាធារណៈ ជាមួយរដ្ឋមន្ត្រីក្រសួងសុខាភិបាលជាតិ និងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់។ សវនាការបានបញ្ចប់ទៅជាមួយនឹងសេចក្តីប្រកាសទទួលស្គាល់សិទ្ធិក្នុងការទទួលបានសុខភាពល្អរបស់ពលរដ្ឋឥណ្ឌា និងអនុសាសន៍ណែនាំឲ្យបង្កើនថវិកាជាតិលើវិស័យសុខាភិបាល ដើម្បីធានានូវការថែទាំសុខភាពប្រកបដោយគុណភាពសម្រាប់ប្រជាជនឥណ្ឌាគ្រប់រូប។

ទោះបីជាការផ្លាស់ប្តូរជាច្រើននៅមិនទាន់អនុវត្តបាននៅឡើយក្តី ក៏ប៉ុន្តែការងាររបស់ក្រុមស្ត្រីពីទីក្រុង Bangalore បានធ្វើឲ្យមានការកែលម្អសេវាថែទាំសុខភាពនៅប្រទេសឥណ្ឌា និងក៏បានជំរុញទឹកចិត្តអ្នកដទៃរួចមកហើយ។ សកម្មជនសុខភាពនៅជុំវិញពិភពលោកបានរៀបចំសវនាការសុខភាពប្រជាជន ដើម្បីពិនិត្យមើលការបំពានសិទ្ធិប្រជាជន ដោយសារកង្វះសេវាសុខភាព ឥទ្ធិពលអាក្រក់លើសុខភាពបណ្តាលមកពីឧស្សាហកម្មរ៉ែនិងប្រេង និងប្រាក់ឈ្នួលទាបសម្រាប់កម្មករជាស្ត្រីនៅតាមរោងចក្រកាត់ដេរសម្លៀកបំពាក់។


www.hesperian.org health guides

## គណនេយ្យភាពថវិកា

ការតាមដានរបៀបដែលមូលនិធិសាធារណៈសម្រាប់ការថែទាំសុខភាព ត្រូវបានចំណាយជាក់ស្តែងនៅក្នុងគ្លីនិកក្នុងស្រុករបស់អ្នក  គឺជាផ្នែកមួយផ្សេងទៀតនៃសវនកម្មសង្គម។ ការពិភាក្សាជាសាធារណៈអំពីរបៀបធ្វើសេចក្តីសម្រេចចិត្តលើផ្នែកអាទិភាពសម្រាប់ផ្តល់មូលនិធិ និងថាតើរដ្ឋាភិបាលបានផ្តល់ថវិកាគ្រប់គ្រាន់សម្រាប់ផ្នែកអាទិភាពទាំងនោះដែរឬទេ ក៏ជាការដាក់សម្ពាធឲ្យរដ្ឋាភិបាលទទួលខុសត្រូវលើការគាំទ្រសិទ្ធិទទួលបានការថែទាំសុខភាពរបស់ប្រជាជនគ្រប់រូបផងដែរ។

ការងាររៀបចំក្រុមរបស់សមាជិកសហគមន៍ក្នុងទីក្រុងវីលកាស (Vilcas) ប្រទេសប៉េរូ នៅក្នុងជំពូក ២ គឺជាឧទាហរណ៍មួយបង្ហាញពីការរៀបចំក្រុមប្រកបដោយភាពជោគជ័យដើម្បីជំរុញឲ្យរដ្ឋាភិបាលបែងចែកប្រាក់សម្រាប់សុខភាពស្ត្រីជាអចិន្ត្រៃយ៍។ កិច្ចខិតខំប្រឹងប្រែងរៀបចំក្រុមរបស់ពួកគេ ក៏បានជួយឲ្យអ្នកដទៃបានរៀនសូត្រអំពីថវិកាសុខភាពរបស់ប្រទេសប៉េរូ ផងដែរ។

### ការរៀនសូត្រអំពីថវិកាសុខភាព នាំទៅចល់ការផ្លាស់ប្តូរនៅប្រទេសប៉េរូ

ស្ត្រីនៅក្នុងសហគមន៍ដាច់ស្រយាលមួយក្នុងប្រទេសប៉េរូ ដែលមានចម្ងាយរាប់រយគីឡូម៉ែត្រពីក្រុង បានរៀនសូត្រអំពីការងាររបស់ក្រុមសំឡេងស្ត្រីក្រុងវីលកាស តាមរយៈកម្មវិធីវិទ្យុ និងបណ្តាញដទៃទៀត។ ពួកគេបានយល់ដឹងថា ពួកគេអាចទទួលព័ត៌មានតាមប្រព័ន្ធអ៊ីនធឺណិត អំពីរបៀបដែលថវិការដ្ឋាភិបាលគួរតែចំណាយលើអ្វីខ្លះ។ ពួកគេបានយល់ដឹងថា ទោះបីជាសហគមន៍ពួកគេគួរទទួលបានថវិកាសម្រាប់សេវាសុខភាពស្ត្រីក៏ដោយ ក៏ប៉ុន្តែមណ្ឌលសុខភាពក្នុងស្រុកមិនបានផ្តល់សេវាទាំងនោះទេ។ ស្ត្រីទាំងនេះបានរៀបចំការហែក្បួនមួយទៅកាន់ការិយាល័យអភិបាលក្រុង ដើម្បីទាមទារការគាំទ្របន្ថែមសម្រាប់សុខភាពស្ត្រី។




ចាប់តាំងពីពេលនោះមក ក្រុមនេះអាចជំរុញឲ្យមេដឹកនាំក្នុងមូលដ្ឋានមានការទទួលខុសត្រូវ ហើយមណ្ឌលសុខភាពបានផ្តល់សេវាសុខភាពបន្ថែមសម្រាប់ស្ត្រី។

# ការពារសេវាសុខភាពសាធារណៈ

ការរៀបចំក្រុមដើម្បីកែលម្អសុខភាពសម្រាប់ស្ត្រី រួមមានការតស៊ូប្រឆាំងនឹងអំពើរើសអើង ភាពក្រីក្រ និងគោលនយោបាយរដ្ឋាភិបាលដែលមិនកំណត់យកតម្រូវការរបស់ស្ត្រី និងក្មេងស្រីជាវិស័យអាទិភាព។ ជារឿយៗ ការរៀបចំក្រុមក៏ពាក់ព័ន្ធនឹងការប្រឆាំងនឹងគោលនយោបាយរដ្ឋាភិបាលដែលអនុញ្ញាតឲ្យក្រុមហ៊ុនឯកជនកាន់កាប់ និងទាញយកផលចំណេញពីសេវាមូលដ្ឋានដែលប្រជាជនគ្រប់រូបត្រូវការជាចាំបាច់ដើម្បីរស់និងមានសុខភាពល្អផងដែរ។ នៅតាមប្រទេសជាច្រើន ទាំងប្រទេសអ្នកមាន និងប្រទេសក្រីក្រ រដ្ឋាភិបាលបានបញ្ឈប់ការផ្ដល់សេវាថែទាំសុខភាព ទឹក អគ្គិសនី និងសេវាផ្សេងៗទៀត។ ជំនួសមកវិញ ក្រុមហ៊ុនឯកជនបានកាន់កាប់សេវាទាំងនេះ ទោះបីជាសេវាទាំងនេះត្រូវបានកសាងរចនាសម្ព័ន្ធឡើងដោយប្រើប្រាស់មូលនិធិសាធារណៈក៏ដោយ។ ការអនុវត្តរបៀបនេះត្រូវបានគេហៅថា "ឯកជនភាវូបនីយកម្ម" ។

មិនដូចរដ្ឋាភិបាល ក្រុមហ៊ុនឯកជនមិនមានការទទួលខុសត្រូវចំពោះប្រជាជនដែលពួកគេត្រូវបម្រើសេវាជូននោះទេ ហើយពួកគេមិនអនុញ្ញាតឲ្យស្ត្រី និងបុរសនៅក្នុងសហគមន៍មានមតិយោបល់លើរបៀបនៃការផ្ដល់សេវាទាំងនោះទេ។ ផ្ទុយមកវិញ ក្រុមហ៊ុនទាំងនោះយកថ្លៃសេវាខ្ពស់បំផុតតាមដែលអាចធ្វើទៅបាន ហើយពួកគេបញ្ឈប់ការផ្ដល់សេវាទាំងឡាយណាដែលមិនផ្ដល់ "ប្រាក់ចំណេញ" ទោះបីជាសេវាទាំងនោះសំខាន់ ឬចាំបាច់ប៉ុណ្ណាក៏ដោយ។

ការអនុវត្តគោលនយោបាយឯកជនភាវូបនីយកម្ម អនុញ្ញាតឲ្យពួកអ្នកមានបន្តទទួលប្រាក់ចំណេញកាន់តែច្រើន ខណៈដែលសុខភាពរបស់ស្ត្រីក្រីក្រ និងកូនៗរបស់ពួកគេរងគ្រោះខ្លាំងបំផុត។

## វេជ្ជបណ្ឌិតតស៊ូមតិដើម្បីសុខភាពប្រជាជន ៖ ការហែក្បួនពណ៌ស នៅប្រទេសអែលសាល់វ៉ាឌ័រ

នៅប្រទេសអែលសាល់វ៉ាឌ័រ បុគ្គលិកសុខាភិបាលបានព្យាយាមតស៊ូដើម្បីកែលម្អសេវាសុខភាពសម្រាប់ប្រជាជនគ្រប់រូប។ ចាប់តាំងពីសង្គ្រាមស៊ីវិលបានបញ្ចប់នៅក្នុងឆ្នាំ១៩៩២ មក សហជីពបុគ្គលិកសុខាភិបាល និងសម្ពន្ធមិត្តរបស់ពួកគេបានតស៊ូប្រឆាំងនឹងការធ្វើឯកជនភាវូបនីយកម្មសេវាថែទាំសុខភាព ខណៈដែលកំពុងតស៊ូដើម្បីកំណែទម្រង់សុខភាព និងការកែលម្អលទ្ធភាពទទួលបានថ្នាំពេទ្យ។

នៅចុងឆ្នាំ២០០២ វេជ្ជបណ្ឌិត និងគិលានុបដ្ឋាក-យិកាក្នុងប្រព័ន្ធសុខភាពសាធារណៈបានធ្វើកូដកម្មប្រឆាំងនឹងការធ្វើឯកជនភាវូបនីយកម្មប្រព័ន្ធសុខភាពសាធារណៈ។ ឯកជនភាវូបនីយកម្មកើតឡើងនៅពេលដែលរដ្ឋាភិបាលបង់ប្រាក់ឲ្យក្រុមហ៊ុនឯកជនផ្ដល់សេវាដែលធ្លាប់ផ្ដល់ដោយរដ្ឋាភិបាល ឬនៅពេលដែលរដ្ឋាភិបាលលក់ទ្រព្យសម្បត្តិរដ្ឋដូចជាសាលារៀន ឬមន្ទីរពេទ្យ ទៅឲ្យក្រុមហ៊ុនឯកជន។ ទោះបីជាការធ្វើឯកជនភាវូបនីយកម្មសេវាថែទាំសុខភាពគឺជារឿងថ្មីថ្មោងនៅក្នុងនៅប្រទេសអែលសាល់វ៉ាឌ័រក៏ដោយក្ដី ក៏ប៉ុន្តែបុគ្គលិកសុខាភិបាល និងអ្នកជំងឺបានដឹងពីអ្វីដែលរំពឹងថានឹងកើតឡើង។ នៅក្នុងអំឡុងទសវត្សរ៍កន្លងទៅ វិស័យថាមពល និងគមនាគមន៍ដែលគ្រប់គ្រងដោយរដ្ឋាភិបាល ត្រូវបានធ្វើឯកជនភាវូបនីយកម្ម ដែលធ្វើឲ្យសេវាទាំងនោះមានតម្លៃកាន់តែខ្ពស់។ ដោយធ្លាប់ឆ្លងកាត់បទពិសោធន៍បែបនេះ សកម្មជនបានរំពឹងថា ការថែទាំសេវាសុខភាពដែលផ្ដល់ដោយឯកជន នឹងធ្វើឲ្យការចំណាយកើនឡើងខ្ពស់ និងបានទៅដល់ប្រជាជនក្រីក្រតិចតួច បើប្រៀបធៀបនឹងសេវាដែលគ្រប់គ្រងដោយរដ្ឋាភិបាល។

ជាការឆ្លើយតប បុគ្គលិកសុខាភិបាលបានរៀបចំ "ការហែក្បួនពណ៌ស" ("white marches")ដ៏ធំមួយ ក្នុងនោះបុគ្គលិកសុខាភិបាលដែលភាគច្រើនជាស្ត្រីបានធ្វើបាតុកម្មដោយស្លៀកសម្លៀកបំពាក់ និងឯកសណ្ឋានពណ៌ស។ សម្ពន្ធមិត្តពីអង្គការកសិករ សិស្ស-និស្សិត ពលករ និងស្ត្រីដែលចូលរួមក្នុងការហែក្បួននោះក៏បានស្លៀកពាក់ពណ៌ស ដើម្បីជាការបង្ហាញសាមគ្គីភាពផងដែរ។ ក្រុមស្ត្រីមានសកម្មភាពខ្លាំងក្លាជាងគេ ពីព្រោះពួកគេបានដឹងពីសារៈសំខាន់នៃការថែទាំសុខភាពប្រកបដោយគុណភាពសម្រាប់ស្ត្រី ហើយបុគ្គលិកសុខាភិបាលគាំទ្រសិទ្ធិរបស់ស្ត្រី។ បាតុកម្មបានបន្តរយៈពេល ៩ខែ ដោយមានការដើរហែក្បួន ការអុជទានបួងសួង ការបិទផ្លូវ និងការអង្គុយតវ៉ានៅពាសពេញផ្ទៃប្រទេស។ បន្ទាប់មក សហជីពអ្នកផ្តល់សេវាសុខភាព និងរដ្ឋាភិបាលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយដែលបានបិទបញ្ចប់ដំណើរការឯកជនភាវូបនីយកម្ម។




ប្រាំឆ្នាំក្រោយមក ដំណោះស្រាយដ៏ធំមួយបានកើតមានឡើង នៅពេលដែលគណបក្សនយោបាយថ្មីមួយឡើងកាន់អំណាច។ គណបក្សរណសិរ្សរំដោះជាតិ (FMLN) បានឈ្នះការបោះឆ្នោតជ្រើសរើសប្រធានាធិបតី មួយផ្នែកគឺដោយសារប្រជាប្រិយភាពរបស់គណបក្សជាមួយនឹងបណ្តាក្រុមដែលប្រឆាំងនឹងការធ្វើឯកជនភាវូបនីយកម្ម។ ដោយមានការគាំទ្រនេះ រដ្ឋាភិបាលដឹកនាំ ដោយគណបក្ស FMLN បានកែទម្រង់វិស័យសុខាភិបាលដើម្បីបង្កើនលទ្ធភាព និងគុណភាពនៃការផ្តល់សេវាជូនដល់ប្រជាជនភាគច្រើន។ ពួកគេក៏បានអនុម័តច្បាប់មួយដែលធ្វើឲ្យតម្លៃថ្នាំពេទ្យធ្លាក់ថ្លៃទាប ដោយលុបចោលនូវសិទ្ធិគ្រប់គ្រងការចែកចាយ និងលក់ដូរថ្នាំពេទ្យរបស់សាជីវកម្មអន្តរជាតិ។ សមិទ្ធផលទាំងនេះសម្រេចទៅបានដោយសារតែបុគ្គលិកសុខាភិបាល និងសម្ពន្ធមិត្តរបស់ពួកគេបានធ្វើការអប់រំ រៀបចំក្រុម និងប្រឆាំងតវ៉ាអស់រយៈពេលជាច្រើនឆ្នាំដើម្បីការពារសិទ្ធិទទួលបានការថែទាំសុខភាពរបស់ពួកគេ។

# គាំទ្រការតស៊ូដើម្បីសុខភាពទាំងអស់គ្នា

ការទទួលបានចំណីអាហារ ទឹក លំនៅឋាន ការអប់រំ ការងារដែលមានសុវត្ថិភាព និងប្រាក់ឈ្នួលសមរម្យ និងសេរីភាពពីការរើសអើង គឺជាលក្ខខណ្ឌដែលយើងទាំងអស់គ្នាត្រូវការដើម្បីមានសុខភាពល្អ? ទាំងនេះក៏ជាសិទ្ធិរបស់មនុស្ស និងមូលដ្ឋានគ្រឹះនៃសង្គមមួយដែលមានភាពយុត្តិធម៌ផងដែរ។ សេចក្តីប្រកាស និងច្បាប់អន្តរជាតិបានទទួលស្គាល់សិទ្ធិទាំងនេះថាជាសិទ្ធិសម្រាប់មនុស្សទាំងអស់គ្នា។ ស្ត្រី និងក្មេងស្រីទាំងអស់មានសិទ្ធិរស់នៅប្រកបដោយសុខភាពល្អ និងផលិតភាពខ្ពស់ មិនថាពួកគេមានពណ៌សម្បុរស្បែក មានគ្រួសារជាអ្នកក្រីក្រឬអ្នកមាន ឬរស់នៅក្នុងប្រទេសក្រីក្រឬប្រទេសអ្នកមាននោះទេ។

ការទទួលបានការថែទាំសុខភាពដែលបំពេញនូវតម្រូវការរបស់ប្រជាជនទាំងអស់ ត្រូវបានទទួលស្គាល់ជាសិទ្ធិមនុស្សមួយ។ ស្ត្រី និងក្មេងស្រីទាំងអស់មានសិទ្ធិទទួលបានការថែទាំសុខភាពដែលអាចឲ្យទទួលយកបាននិងមានតម្លៃសមរម្យ ដែលគោរពប្រពៃណីរបស់ពួកគេ និងដែលបំពេញនូវតម្រូវការរបស់ពួកគេ។




មានវិធីជាច្រើនសម្រាប់ធ្វើការងាររៀបចំក្រុមដើម្បីកែលម្អសុខភាព និងលទ្ធភាពទទួលបានសេវាថែទាំសុខភាពរបស់ស្ត្រី។ ស្ត្រីនៅក្នុងទីក្រុងវីលកាស ប្រទេសប៉េរូ (ជំពូក ២) ចាប់បានការកាត់បន្ថយចំនួនស្ត្រីជនជាតិដើមភាគតិចដែលស្លាប់ក្នុងអំឡុងពេលសម្រាលកូន។ ពួកគេទទួលជោគជ័យតាមរយៈការកំណត់គោលដៅនិងយុទ្ធសាស្ត្រ ការបង្កើតសម្ពន្ធមិត្តដោយភាពអត់ធ្មត់ និងការវាយតម្លៃនិងរៀនសូត្រពីការងាររបស់ពួកគេជាប្រចាំ។ ស្ត្រីទាំងបីនាក់ពីទីក្រុងអាមេតដាបាត ប្រទេសឥណ្ឌា (ជំពូក ១០) ចង់ទទួលបានការថែទាំសុខភាពនៅពេលពួកគេមានបញ្ហាសុខភាពទាក់ទងនឹងការងារ។ ពួកគេទទួលជោគជ័យតាមរយៈការចូលរួមជាមួយអង្គការមូលដ្ឋានមួយដែលមានឈ្មោះថាសមាគម SEWA និងការធ្វើការជាមួយសមាគមដើម្បីបង្កើតសម្ពន្ធមិត្តជាមួយមន្ត្រីរដ្ឋាភិបាលដែលទទួលបន្ទុកវិស័យការងារ អ្នកជំនាញផ្នែកសុខភាពការងារ បុគ្គលិកសុខាភិបាល និងស្ត្រីជាកម្មករដទៃទៀត។

កិច្ចខិតខំប្រឹងប្រែងជាច្រើនត្រូវបានរៀបរាប់នៅក្នុងសៀវភៅនេះ រួមទាំងសហគមន៍ពិនិត្យមើលតួនាទីយេនឌ័រឡើងវិញ ប្រជាជនវ័យក្មេងបង្កើនការយល់ដឹងអំពីសុខភាពផ្លូវភេទ សិល្បករប្រើប្រាស់តុក្កតាដើម្បីអប់រំ និងកៀងគរប្រជាជនជុំវិញការបង្ការការចម្លងមេរោគអេដស៍ និងអ្នកជិតខាងស្វែងយល់ពីរបៀបធ្វើឲ្យសហគមន៍កាន់តែមានសុវត្ថិភាពពីអំពើហិង្សាយេនឌ័រ។ ទាំងនេះគឺជាផ្នែកដ៏តូចមួយនៃកិច្ចខិតខំប្រែងរៀបចំក្រុមដែលកំពុងប្រព្រឹត្តទៅនៅជុំវិញពិភពលោក!

នៅក្នុងកិច្ចខិតខំប្រឹងប្រែងនីមួយៗ ប្រជាជនបានចូលរួមសាមគ្គីគ្នាបង្កើតការផ្លាស់ប្តូរ កសាងនូវថ្នាក់ដឹកនាំថ្មីៗពីមូលដ្ឋាន និងអភិវឌ្ឍបណ្តាញទំនាក់ទំនង និងចំណេះដឹង ដែលធ្វើឲ្យពួកគេកាន់តែមានកម្លាំងខ្លាំងនៅក្នុងការតស៊ូនាពេលខាងមុខ។ ពួកគេបានជួបប្រទះបញ្ហាប្រឈម និងថែមទាំងការគំរាមកំហែង ប៉ុន្តែតាមរយៈការរក្សាការប្តេជ្ញាចិត្តចំពោះគោលដៅរបស់ពួកគេ ពួកគេបានសង្គ្រោះជីវិត បានកែលម្អស្ថានភាពសុខភាពរបស់មនុស្សជាច្រើន និងបានធ្វើឲ្យសហគមន៍ពួកគេកាន់តែមានភាពយុត្តិធម៌ និងសមធម៌។


www.hesperian.org health guides

តាមរយៈការចែករំលែកគំនិតនិងបទពិសោធន៍ និងការបរាជ័យនិងភាពជោគជ័យ ការងាររបស់អ្នករៀបចំក្រុមទាំងនេះក៏មានឥទ្ធិពលសាយភាយផងដែរ ពីព្រោះវាបានជូនដំណឹង ជំរុញទឹកចិត្ត និងគាំទ្រដល់អ្នកដទៃបន្តទៀត។ ពួកគេអាចជាអ្នករស់នៅក្បែរគ្នាក្នុងសហគមន៍តែមួយ ឬឆ្ងាយពីគ្នានៅលើផែនដីតែមួយ។ ស្ត្រីនិងបុរសគ្រប់វ័យទាំងអស់បានក្លាយជាផ្នែកមួយនៃចលនាដែលមានភាពចម្រុះ និងផ្សព្វផ្សាយដើម្បីទាមទារនូវសិទ្ធិទទួលបានសុខភាពល្អសម្រាប់ប្រជាជនទាំងអស់។ ពួកគេ និងពួកយើងខ្ញុំសូមអញ្ជើញអ្នកមកចូលរួមជាមួយពួកយើងទាំងអស់គ្នា។

